Public Disclosure Authorized

Public Disclosure Authorized

20888



ទស្សនៈរួម

# ការចាប់ផ្តើមដោះស្រាយភាពក្រីក្រ៖ ការលានុវត្តភាព ការផ្តល់អំណាច និង សន្តិសុខ

ប្រជាជនក្រីក្ររស់នៅដោយគ្មានសេរីភាពនិងការជ្រើសរើស ដែលគេយល់ថា ត្រូវតែធ្វើឱ្យបានប្រសើរជាងនេះ[១] ។ ជារឿយៗពួកគេខ្វះខាតនូវចំណីអាហារ និងទីជំរក ការអប់រំនិងសុខាភិបាល និងភាពខ្វះខាតផ្សេងៗ ដែលធ្វើអោយពួកគេមិនបានឈានទៅដល់កំរិតនៃជីវភាពមួយដែលគេរាល់គ្នាមាន។ ប្រជាជនទាំងនោះក៏ប្រឈមមុខផងដែរ ទៅនឹងភាពងាយធ្វើអោយប៉ះពាល់ដល់សុខភាព ការបែកបាក់ដល់សេដ្ឋកិច្ច និងគ្រោះមហន្តរាយធម្មជាតិ។ ហើយជាញឹកញាប់ពួកគេត្រូវបានស្ថាបន្យនានារបស់រដ្ឋ និងសង្គមមើលងាយ ហើយពួកគ្មានឥទ្ធិពលលើសេចក្តីសំរេចចិត្តសំខាន់ៗ ដែលជះឥទ្ធិពលដល់ការរស់នៅរបស់ពួកគេទេ។ ទាំងនេះគឺជាទំហំនៃភាពក្រីក្រ។

បទពិសោធន៍នៃការខូចខាតដ៏ច្រើនសន្ធឹកសន្ធាប់គឺមានលក្ខណៈខ្លាំងក្លា និងពោរពេញទៅដោយការឈឺចាប់។ ការពិពណ៌នារបស់ប្រជាជនក្រីក្រអំពីការរស់នៅក្នុងភាពក្រីក្រគឺជាសក្ខីភាពបញ្ជាក់អោយឃើញអំពីការឈឺចាប់របស់ពួកគេ (ប្រអប់ ១)។ ចំពោះអ្នកទាំងឡាយដែលរស់នៅក្នុងភាពក្រីក្រ ការគេចចេញពីភាពក្រីក្រហាក់ដូចជាមិនអាចធ្វើទៅបានទេ។ ក៏ប៉ុន្តែវាក៏មិនប្រាកដថា ចៀសមិនរួចដែរ។ រឿងរបស់អ្នកស្រី Basrabai (ជាប្រធានក្រុមប្រឹក្សាមូលដ្ឋាននៅក្នុងភូមិមួយរបស់ប្រទេសឥណ្ឌា) បានបកស្រាយលក្ខណៈជាច្រើននៃភាពក្រីក្រនិងសក្តានុពលភាពសំរាប់ការអនុវត្ត (ចូរអានទំព័រ ២)។

រឿងរបស់អ្នកស្រី Basrabai ផ្តល់ជាសវតាមួយសំរាប់ការរុករកធម្មជាតិនិងបុព្វហេតុនៃភាពក្រីក្រ និងអំពីអ្វីៗដែលអាចធ្វើទៅបាន។ ភាពក្រីក្រគឺជាលទ្ធផលនៃដំណើរការរបស់សេដ្ឋកិច្ច នយោបាយ និងសង្គម ដែលវាមានអន្តរកម្មទៅលើគ្នាទៅវិញទៅមក ហើយជាញឹកញាប់វាបំពេញគ្នាទៅវិញទៅមកតាមវិធីផ្សេងៗដែលធ្វើអោយភាពខ្វះខាតរបស់ប្រជាជនក្រីក្រកាន់តែធ្ងន់ធ្ងរឡើង។ ទ្រព្យសម្បត្តិបន្តិចបន្តួចទីផ្សារចូលមិនចុះ និងឱកាសការងារកម្រ បានធ្វើអោយប្រជាជនជាប់គាំងនៅក្នុងភាពក្រីក្រខាងផ្នែកសំភារៈ។ អាស្រ័យហេតុនេះហើយបានជាការជំរុញ

អោយមានកាលានុវត្តភាព (តាមរយៈការជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ការធ្វើអោយទីផ្សារដំណើរការទៅបានល្អប្រសើរសំរាប់ប្រជាជនក្រីក្រ ហើយនិងតាមរយៈការបង្កើតទ្រព្យសម្បត្តិរបស់ពួកគេ) គឺមានសារសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។

ក៏ប៉ុន្តែនេះគ្រាន់តែជាផ្នែកមួយនៃរឿងប៉ុណ្ណោះ ។ នៅក្នុងពិភពលោកមួយដែលអំណាចនយោបាយត្រូវបានបែងចែកមិនស្មើភាព និងជាញឹកញាប់ធ្វើតាមការបែងចែកអំណាចសេដ្ឋកិច្ចដែលជាវិធីមួយដែលស្ថាបន្យរបស់រដ្ឋប្រតិបត្តិនោះអាចជាចំនុចអវិជ្ជមានយ៉ាងពិសេសសំរាប់ប្រជាជនក្រីក្រ ។ ឧទាហរណ៍ ជាញឹកញាប់ប្រជាជនក្រីក្រមិនបានទទួលនូវផលប្រយោជន៍ពីវិនិយោគសាធារណៈលើវិស័យអប់រំនិងសុខាភិបាលទេ ។ ហើយជាញឹកញាប់ពួកគេគឺជាជនរងគ្រោះដោយសារតែអំពើពុករលួយ និងអំពើរំលោភបំពាននៅក្នុងផ្នែកមួយរបស់រដ្ឋ ។

## រឿងរបស់អ្នកស្រី Basrabai

*អ្នកស្រី Basrabai រស់នៅក្នុងតំបន់ Mohadi ដែលជាភូមិមួយស្ថិតនៅចំងាយ ៥០០ គីឡូម៉ែត្រពីតំបន់ Ahmedabad ស្ថិតនៅក្នុងរដ្ឋ Gujarat នៃប្រទេសឥណ្ឌាស្ថិតនៅលើឆ្នេរសមុទ្រអារ៉ាប់[២] ។ គាត់គឺជាស្ត្រីទីមួយដែលបានក្លាយជាប្រធានក្រុមប្រឹក្សាតំបន់ដែលជាលទ្ធផលនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដែលបានកំណត់ទុកអសនៈសំរាប់ក្រុមប្រឹក្សាតំបន់ចំនួនមួយភាគបី និងតំណែងជាប្រធានសំរាប់ស្ត្រីចំនួនមួយភាគបី ។*

*មកដល់ក្នុងភូមិរបស់គាត់បន្ទាប់ពីការបើកបរដ៏យូរ យើងបានឆ្លងកាត់ដៃសមុទ្រតូចមួយតាមផ្លូវដែលមិនអាចឆ្លងកាត់បានដោយសារតែទឹកជោរ ។ អាគារដំបូងគេដែលយើងបានឃើញគឺជាសំណង់ដែលសាងសង់អំពីស៊ីម៉ង់ត៍នាពេលថ្មីៗ ។ អាគារនេះគឺជាសាលាបឋមសិក្សា ។ នៅក្នុងខ្យល់ព្យុះកំបុតត្បូងកាលពីឆ្នាំមុន គឺជាគ្រោះមហន្តរាយដ៏អាក្រក់បំផុតក្នុងជីវិតរបស់ពួកគេ ព្រោះថាខ្ទមដែលធ្វើពីចំបើងរបស់អ្នកភូមិទាំងអស់ត្រូវបានខ្យល់បំផ្លាញខ្ទេចខ្ទីអស់ ។ ពួកអ្នកភូមិទាំងនោះបានទៅជ្រកកោននៅក្នុងអាគារដែលមានស្ថេរភាពតែមួយគត់នៅក្នុងភូមិគឺសាលារៀននេះឯង ។ នៅពេលដែលក្រុមជួយសង្គ្រោះបានមកដល់អ្នកភូមិទាំងអស់នោះក៏បានស្នើសុំអាគារស៊ីម៉ង់ត៍បន្ថែមទៀតហើយភូមិនេះឥឡូវមានអាគារចំនួនប្រហែល ១២ ។*

*យើងបានមកដល់ផ្ទះសង់អំពីបេតុងដែលមានបន្ទប់មួយរបស់ Basrabai ដែលស្ថិតនៅជាប់ខ្ទមចំបើងមួយ ។ ក្រោយពីការធ្វើគារវកិច្ចតាមធម្មតារួចមកយើងបានជជែកគ្នាអំពីសាលារៀន ។ ដោយសារតែវាជាថ្ងៃធ្វើការយើងសង្ស័យថាតើយើងអាចអង្គុយនៅក្នុងថ្នាក់រៀនមួយបានរឺក៏មិនបាន ។ Basrabai បានប្រាប់យើងថា គ្រូបង្រៀនមិននៅទីនេះទេ ហើយគាត់មិននៅទីនោះអស់រយៈពេលមួយរយៈកន្លងមកហើយ ។ តាមការពិត គ្រូបង្រៀននោះគាត់មកទីនេះតែម្តងទេក្នុងមួយខែ ។ ដោយមានការការពារពីមន្ត្រីអប់រំស្រុក គាត់បានបំពេញកិច្ចការដែលគាត់ពេញចិត្តបានច្រើនគួរសម ។*

*គ្រូបង្រៀននោះបានមកនៅថ្ងៃបន្ទាប់ ។ មានពាក្យលេចឮដល់គាត់ថា ភូមិនេះមានភ្ញៀវជាច្រើនមកលេង ។ គាត់បានចូលទៅក្នុងផ្ទះរបស់ Basrabai ហើយយើងក៏បានចាប់ផ្តើមជជែកគ្នាអំពីសាលារៀននិង*

ក្មេងៗ។ ដោយជឿទៅលើភ្ញៀវដែលមានការអប់រំថាមានចិត្តគំនិតដូចគ្នា គាត់បានចាប់ផ្តើមបន់ស្រន់សូមកុំអោយមានបញ្ហានិងការលំបាកក្នុងការបង្រៀនក្មេងៗ។ គាត់បាននិយាយយោងដល់ពួកគេថា "ចេញមកពីព្រៃ"។

បញ្ហានេះដូចជាជាច្រើនពេកសំរាប់អ្នកស្រី Meeraiben ដែលជាសមាជិកម្នាក់របស់សមាគមស្ត្រីដែលធ្វើការសំរាប់ខ្លួនឯង (SEWA) ដែលបានរៀបចំដំណើរទស្សនកិច្ចរបស់យើង។ គាត់បានចង្អុលបង្ហាញថា គ្រូបង្រៀននោះទទួលប្រាក់ខែចំនួន ៦.០០០រូពីក្នុងមួយខែ (គឺច្រើនជាង ៦ដង បើធៀបទៅនឹងបន្ទាត់ភាពក្រីក្ររបស់ឥណ្ឌា) នៅក្នុងការងារដ៏មានសុវត្ថិភាពមួយ ហើយបានចង្អុលបង្ហាញថា ការទទួលខុសត្រូវរបស់គាត់យ៉ាងហោចណាស់ត្រូវបង្ហាញអោយឃើញតាមរយៈការងាររបស់គាត់។ មាតាបិតាចង់អោយកូនចៅរបស់ពួកគាត់រៀនអាន និងសរសេរ ទោះបីជាការចូលរៀនមានន័យថា ក្មេងប្រុសៗមិនអាចជួយឪពុករបស់គេក្នុងការនេសាទ និងក្មេងស្រីៗមិនអាចជួយម្តាយរបស់គេដងទឹក និងរកអុស ហើយនិងធ្វើការនៅក្នុងវាលស្រែក៏ដោយ។

បន្ទាប់មក នៅពេលល្ងាច Basrabai បានរៀបចំការប្រជុំនៅក្នុងភូមិ។ មានប្រធានបទសំខាន់ៗចំនួនពីរ។ ប្រធានបទទី១ គឺនិយាយអំពីសំណងថ្លៃខូចខាតដែលបណ្តាលមកពីព្យុះកំបុតត្បូង: ទោះបីជាតំរោងសង្គ្រោះត្រូវបានប្រកាសនៅក្នុងមូលធនរបស់រដ្ឋក៏ដោយ ក៏ការចែកចាយនៅក្នុងមូលដ្ឋាននៅតែត្រូវការច្រើនបន្ថែមទៀត ហើយមន្ត្រីនៅតាមមូលដ្ឋានមិនអើពើចំពោះបញ្ហានេះទេ។ អ្នករៀបចំ SEWA បានកត់ឈ្មោះអ្នកភូមិទាំងឡាយណាដែលមិនទាន់បានទទួលសំណងថ្លៃខូចខាតដែលខ្លួនមានសិទ្ធិទទួល ហើយមានការយល់ព្រមថាពួកអ្នកភូមិទាំងនោះនិងអ្នកស្រី Basrabai នឹងជួបដើម្បីពិភាក្សាគ្នាជាមួយនិងមន្ត្រីតាមមូលដ្ឋាននៅសប្តាហ៍ក្រោយ។

ប្រធានបទទី ២ គឺនិយាយអំពីការហាមឃាត់ការនេសាទដែលរដ្ឋាភិបាលបានហាមមិនអោយធ្វើការនេសាទនៅលើដែនទឹកក្បែរឆ្នេរក្នុងគោលបំណងដើម្បីការពារពូជត្រី។ គឺចង់សំដៅទៅលើទូកអូសអួនធំៗដែលទទួលខុសត្រូវចំពោះការនេសាទច្រើនហួសកំណត់បណ្តាលអោយហិនហោចពូជត្រី ក៏ប៉ុន្តែអ្នកនេសាទតូចតាចហាក់ដូចជាកំពុងបង់ថ្លៃនេសាទ។ ទូកអូសអួនធំៗអាចបន្តការនេសាទបានដរាបណាពួកគេបង់ថ្លៃនេសាទដល់មន្ត្រីដែលទទួលបន្ទុកកិច្ចការនេះ។

នៅពាក់កណ្តាលនៃអង្គប្រជុំ មានការភ្ញាក់ផ្អើលមួយបានកើតឡើង។ បងប្រុសរបស់ Basrabai ត្រូវបានគោជល់ចំមុខ ក្នុងខណៈដែលគាត់កំពុងតែព្យាយាមបំបែកគោពីរដែលកំពុងជុលគ្នា។ បើគ្មានការព្យាបាលបន្ទាន់មុខរបួសនោះមុខជានឹងក្លាយ។ ក៏ប៉ុន្តែវាយប់ជ្រៅណាស់ទៅហើយ ហើយវេជ្ជបណ្ឌិតដែលនៅជិតជាងគេបំផុតស្ថិតនៅក្នុងតំបន់ធំមួយដែលមានចំងាយ 10 គីឡូម៉ែត្រពីភូមិនេះ។ តាមធម្មតាការព្យាបាលបន្ទាន់មិនអាចធ្វើទៅបានទេ។ ក៏ប៉ុន្តែនៅពេលដែលគ្រោះថ្នាក់នោះបានកើតឡើង រថយន្តហ្ស៊ីបរបស់យើងក៏នៅទីនោះដែរ ហើយអាចដឹកបងប្រុសរបស់ Basrabai ទៅរកវេជ្ជបណ្ឌិតនោះ។

ក្នុងកំឡុងពេលស្នាក់នៅរបស់យើង យើងក៏បានឃើញការងារសិប្បកម្ម ដែលស្ត្រីក្នុងភូមិបានកំពុងធ្វើ

សំរាប់ជំនាន់របស់ពួកគេ ។ តំរូវការសំរាប់ផលិតផលប៉ាក់និងជ្រលក់ពណ៌បែបបុរាណរបស់ពួកគេ មានកំរិតខ្ពស់ សូមថ្លែងអំណរគុណចំពោះការចាប់អារម្មណ៏ពីអន្តរជាតិចំពោះផលិតផលរបស់ប្រទេសឥណ្ឌា និងរបបគំហើញម្តងទៀតតាមរយៈការង្កើតការលើកទឹកចិត្តថ្នាក់កណ្តាលរបស់ឥណ្ឌា ។ ប៉ុន្តែឈ្មួញជាច្រើនរួចផុតពីការបង់ថ្លៃទាប ដោយសារតែភាពឯកោរបស់ស្ត្រី ។

រដ្ឋាភិបាលមានគំរោងច្រើនរាប់មិនអស់ដើម្បីគាំទ្រដល់សិប្បកម្មបុរាណ ។ ដូច្នោះ SEWA កំពុងតែចូលរួមដើម្បីរៀបចំ សិប្បករនៅតាមផ្ទះនិងផ្តល់ឱកាសផ្ទាល់ក្នុងការឈានចូលទីផ្សារអន្តរជាតិ ។ ផលិតផលប៉ាក់មួយផ្ទាំងដែលយើងបានមើលមានតំលៃ 150 រូបពីនៅក្នុងទីផ្សារអន្តរជាតិ 60 រូបពីនៅក្នុងទីផ្សាររបស់រដ្ឋាភិបាល និង 20 រូបពី ពីឈ្មួញ ។

នៅថ្ងៃចុងក្រោយនៃការស្នាក់នៅរបស់យើង យើងបានទៅកាន់វាលស្រែរបស់អ្នកស្រី Basrabai ដែលដើរចេញពីផ្ទះរបស់គាត់ទៅ ត្រូវប្រើរយៈពេលអស់មួយម៉ោង ។ ហានិភ័យនៃកសិកម្មត្រូវបានមើលឃើញយ៉ាងច្បាស់ ។ កង្វះខាតទឹកភ្លៀងបានធ្វើអោយដីស្ងួតហើយរឹង ។ ប្រសិនបើវាមិនភ្លៀងនៅក្នុងរយៈពេលពីរ រឺ បីថ្ងៃខាងមុខនោះទេ ស្រូវមីយេរបស់គាត់នឹងត្រូវខូចខាត ហើយគាត់ត្រូវចំណាយទៅលើថ្លៃឈ្នួលអ្នកបើកបរត្រាក់ទ័រដើម្បីអោយភ្ជួរវាលស្រែរបស់គាត់ ការធ្វើវិនិយោគទុនមួយអាចធ្វើទៅបានដោយសារការលក់ផលិតផលសិប្បកម្មរបស់គាត់ ។ នៅពេលដែលយើងបានជួបគាត់នៅឯ Ahmedabad ប៉ុន្មានថ្ងៃក្រោយវានៅតែមិនភ្លៀង ។

អន្តរកម្មរវាងអ្នកស្រី Basrabai ជាមួយនិងប្រជាជនក្រីក្រជាច្រើនពាន់នាក់ដែលត្រូវបានពិគ្រោះគ្នាក្នុងការរៀបចំរបាយការណ៏នេះ នាំទៅដល់ការបង្កើតអោយមានជាប្រធានបទជាច្រើនជាបន្តបន្ទាប់ ហើយនិងអាចទទួលស្គាល់បាន ។ ប្រជាជនក្រីក្រនិយាយអំពីកង្វះខាតឱកាសក្នុងការរកប្រាក់ចំណូល អំពីទំនាក់ទំនងមិនល្អជាមួយទីផ្សារ ហើយនិងការបរាជ័យរបស់ស្ថាបន្យរដ្ឋក្នុងការឆ្លើយតបទៅនិងតំរូវរបស់ប្រជាជនក្រីក្រ ។ ពួកគេនិយាយអំពីអសន្តិសុខដូចជាគ្រោះថ្នាក់នៃសុខភាព គ្រោះថ្នាក់នៃការអត់ការងារធ្វើ ហើយនិងគ្រោះថ្នាក់នៃកសិកម្មដែលតែងតែធ្វើអោយមានការខាតបង់ ។ នៅគ្រប់ទីកន្លែង（ពីភូមិនានានៅក្នុងប្រទេសឥណ្ឌារហូតដល់តំបន់ Favelas នៃទីក្រុង Rio de Janeiro តំបន់នៃទីក្រុងដែលមានខ្ទមច្រើននៅខាងក្រៅទីក្រុង Johanesburg ហើយនិងចំការនៅក្នុងតំបន់ Uzbekistan） រឿងទាំងនេះបង្ហាញអោយឃើញនូវបញ្ហាស្រដៀងគ្នាជាច្រើន ។

ក៏ប៉ុន្តែការជជែកគ្នាជាមួយអ្នកស្រី Basrabai និងប្រជាជនក្រីក្រដទៃផ្សេងទៀតក៏បានបង្ហាញអោយឃើញពីអ្វីដែលនិងអាចធ្វើទៅបានផងដែរ ។ ទោះបីជាមន្ត្រីនៅតាមមូលដ្ឋាន និងរចនាសម្ព័ន្ធរបស់រដ្ឋនៅមិនទាន់អាចទទួលខុសត្រូវចំពោះអ្នកស្រី Basrabai និងភូមិរបស់គាត់ក៏ដោយ ក៏គោលនយោបាយទប់ស្កាត់ការរើសអើងឬប្រកាន់ជាតិសាសន៏ក្នុងការងារជាក់ស្តែងបានអនុញ្ញាតិអោយមានការបោះឆ្នោតជ្រើសរើសអ្នកស្រី Basrabai អោយធ្វើជាប្រធានក្រុមប្រឹក្សាមូលដ្ឋានដែរ នេះបង្ហាញអោយឃើញពីអ្វីដែលអាចធ្វើទៅបានតាមរយៈការអនុវត្តរបស់

*រដ្ឋ។ ហើយ SEWA បានបង្ហាញពីរបៀបដែលប្រជាជនក្រីក្រអាចបង្កើតនូវភាពខុសគ្នាមួយប្រសិនបើពួកគេរៀបចំខ្លួនឯងដើម្បីការពារសិទ្ធិរបស់ខ្លួន ដើម្បីទាញយកផលប្រយោជន៍នៃឱកាសទីផ្សារ ហើយនិងដើម្បីការពារខ្លួនគេផ្ទាល់ អោយផុតពីគ្រោះថ្នាក់ផ្សេងៗ។*

---

## ប្រអប់ ១

## សំលេងរបស់ប្រជាជនក្រីក្រ

---

ការសិក្សាអំពីសំលេងរបស់អ្នកក្រីក្រដែលពឹងផ្អែកជាមូលដ្ឋានទៅលើការពិតនានាទទួលបានពីបុរសនិងស្ត្រីចំនួនច្រើនជាង 60.000 នាក់ នៅក្នុងប្រទេសចំនួន 60 ត្រូវបានធ្វើឡើងជាសាវតារសំរាប់របាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ 2000/2001 ។ ការសិក្សានេះចែកចេញជាពីរផ្នែកៈការត្រួតពិនិត្យមើលឡើងវិញលើការសិក្សាថ្មីៗដែលទាមទារអោយមានការចូលរួម ស្តីអំពីភាពក្រីក្រ នៅក្នុងប្រទេសចំនួន 50 ដែលមានប្រជាជនក្រីក្រប្រហែល 40.000 នាក់ ហើយនិងការសិក្សាប្រៀបធៀបថ្មីមួយនៅក្នុងឆ្នាំ 1999 នៅក្នុងប្រទេសចំនួន 23 ដែលមានប្រជាជនប្រហែល 20.000 នាក់។ ការសិក្សានេះបង្ហាញថាប្រជាជនក្រីក្រគឺជាភ្នាក់ងារសកម្មនៅក្នុងជីវភាពរស់នៅរបស់ពួកគេ ក៏ប៉ុន្តែជាញឹកញាប់ពុំមានឥទ្ធិពលទៅកត្តាសេដ្ឋកិច្ចនិងសង្គម ដែលកំណត់អំពីសុខមាលភាពរបស់ពួកគេទេ។

សំដីដកស្រង់ខាងក្រោមនេះគឺជាការបកស្រាយមួយថាតើការរស់នៅក្នុងភាពក្រីក្រមានន័យយ៉ាងដូចម្តេច។

*កុំសួរខ្ញុំថាតើអ្វីទៅជាភាពក្រីក្រ ពីព្រោះអ្នកបានជួបវានៅខាងក្រៅផ្ទះរបស់ខ្ញុំរួចទៅហើយ។ ចូរក្រឡេកមើលផ្ទះហើយរាប់ចំនួនរន្ធធ្លុះធ្លាយ។ ចូរក្រឡេកមើលគ្រឿងប្រដាប់ក្នុងផ្ទះបាយនិងសំលៀកបំពាក់ដែលខ្ញុំកំពុងស្លៀកពាក់។ ចូរក្រឡេកមើលអ្វីៗ ហើយសរសេរនូវអ្វីដែលអ្នកបានឃើញ។ អ្វីដែលអ្នកបានឃើញនោះគឺជាភាពក្រីក្រហើយ។*

*___បុរសក្រីក្រ,ប្រទេស Kenya*

*ពិតប្រាកដណាស់ ការធ្វើស្រែចំការរបស់ពួកយើងមានចំនួនតិចតួច។ គ្រប់ផលិតផលទាំងអស់ របស់របរដែលបានទិញពីហាងទំនិញមានតំលៃថ្លៃ។ វាមានការលំបាកក្នុងការរស់នៅ យើងធ្វើការនិងចំណេញបានប្រាក់បន្តិចបន្តួចទិញរបស់របរឬផលិតផលបន្តិចបន្តួច។ ផលិតផលទាំងនោះកម្រ គ្មានលុយហើយយើងមានអារម្មណ៍ថា ក្រ។ ប្រសិនបើមានលុយ...*

*__ពីក្រុមពិភាក្សាអំពីបុរសនិងស្ត្រីក្រីក្រ, Ecuador*

*យើងជួបប្រទះការលំបាកនៅពេលដែលស្វាមីរបស់ខ្ញុំធ្លាក់ខ្លួនឈឺ។ ជីវិតរបស់យើងលែងដើរទៅមុខរហូតទាល់តែគាត់ជាសះស្បើយហើយត្រឡប់ទៅធ្វើការវិញ។*

*__ស្ត្រីក្រីក្រ, Zawyet, Egypt*

*ភាពក្រីក្រគឺជាភាពអាម៉ាស់ អារម្មណ៍នៃការពឹងផ្អែកទៅលើគេនិងអារម្មណ៍នៃការត្រូវគេបង្ខំអោយទទួលយកអ្វីនូវភាពទ្រគោះ ភាពធ្វើអោយអាម៉ាស់មុខហើយនិងភាពព្រងើយកន្តើយ នៅពេលដែលយើងស្នើសុំអោយគេជួយ។*

*__ស្ត្រីក្រីក្រ, Latvia*

*ជាដំបូង ខ្ញុំខ្លាចគេវាល់គ្នានិងខ្លាចអ្វីៗទាំង : ស្វាមីរបស់ខ្ញុំ ប្រធានភូមិ ប៉ូលិស។ ថ្ងៃនេះខ្ញុំមិនខ្លាចនរណាទាំងអស់។ ខ្ញុំមានកុងធនាគារផ្ទាល់ខ្លួនរបស់ខ្ញុំ ខ្ញុំគឺជាប្រធានក្រុមសញ្ច័យរបស់ភូមិខ្ញុំ... ខ្ញុំប្រាប់បងប្អូនស្រីរបស់ខ្ញុំអំពីនិទ្ទាការរបស់ខ្ញុំ។ ហើយយើងមានសហគមមួយដែលមានសមាជិក 40.000 នាក់ នៅក្នុងស្រុក។*

*—ពីក្រុមពិភាក្សាអំពីស្ត្រីនិងបុរសក្រីក្រ, India*

*ប្រភព:* Narayan, Chambers, Shah and Petesch 2000; Narayan, Patel, Schafft, Rademacher, and Koch-Schulte 2000.

លទ្ធផលនៃភាពក្រីក្រក៏ត្រូវទទួលផលប៉ះពាល់យ៉ាងខ្លាំងពីបទដ្ឋានសង្គម តំលៃ និងការប្រតិបត្តិតាមទំលាប់ ដែល(នៅក្នុងគ្រួសារ សហគម រឺ ទីផ្សារ) នាំទៅដល់ការរើសអើងស្ត្រី ក្រុមប្រកាន់ជាតិសាសន៍ និងជាតិពន្ធ រឺក៏នាំទៅដល់ការធ្វើអោយខូចអត្ថប្រយោជន៍ដល់សង្គម។ អាស្រ័យហេតុនេះហើយការសំរួលដល់ការផ្តល់អំណាយដល់ប្រជាជនក្រីក្រ (ដោយធ្វើអោយស្ថាបន្យសង្គមនិងរដ្ឋ យកចិត្តទុកដាក់ដល់ពួកគេបន្ថែមទៀត) ក៏មានសារៈសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រដែរ។

ភាពងាយធ្វើអោយឈឺចាប់ ចំពោះព្រឹត្តការណ៍ខាងក្រៅនិងដែលមិនអាចគ្រប់គ្រងបាន (ដូចជាជំងឺ អំពើហិង្សា ផលប៉ះពាល់សេដ្ឋកិច្ច អាកាសធាតុមិនល្អ គ្រោះមហន្តរាយធម្មជាតិ) បង្កើននូវអារម្មណ៍គ្មានសុភមង្គលរបស់ប្រជាជនក្រីក្រ ធ្វើអោយភាពក្រីក្រផ្នែកសំភារៈរបស់ពួកគេកាន់តែធ្ងន់ធ្ងរឡើងហើយនិងធ្វើអោយតួនាទីចរចារបស់ពួកគេចុះខ្សោយ។ អាស្រ័យហេតុនេះហើយ ការលើកកំពស់សន្តិសុខ (តាមរយៈការកាត់បន្ថយគ្រោះថ្នាក់នៃព្រឹត្តការណ៍ផ្សេងៗដូចជាសង្គ្រាម ជំងឺ វិបត្តិសេដ្ឋកិច្ច និងគ្រោះមហន្តរាយធម្មជាតិ) គឺមានសារៈសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ។ ហើយវាក៏ដូចគ្នាដែរចំពោះការកាត់បន្ថយភាពឈឺចាប់របស់ប្រជាជនក្រីក្រដែលបណ្តាលមកពីគ្រោះថ្នាក់ផ្សេងៗ និងរៀបចំយន្តការនានាអោយបានត្រឹមត្រូវដើម្បីជួយពួកគេទប់ទល់និងផលប៉ះពាល់មិនល្អ។

### ភាពក្រីក្រនៅក្នុងពិភពលោកមួយដែលមិនស្មើភាព

ពិភពលោកមានភាពក្រីក្រច្រើន។ ក្នុងចំណោមប្រជាជន 6 កោដិនាក់នៅលើពិភពលោក មានប្រជាជន 2,8 កោដិនាក់ គឺស្មើរតែពាក់កណ្តាលនៃប្រជាជនទាំងអស់នៅលើពិភពលោក រស់នៅអាស្រ័យលើប្រាក់ចំណូលតិចជាង 2 ដុល្លាក្នុងមួយថ្ងៃ និងប្រជាជនចំនួន 1,2 កោដិនាក់ (ស្មើនឹងមួយភាគប្រាំនៃប្រជាជនទូទាំងពិភពលោក) រស់នៅអាស្រ័យលើប្រាក់ចំណូលតិចជាង 1 ដុល្លាក្នុងមួយថ្ងៃ ដែលក្នុងនោះមាន 44 ភាគរយរស់នៅក្នុងតំបន់អាស៊ីខាងត្បូង (រូប១)។ នៅក្នុងប្រទេសអ្នកមានជាច្រើន ក្មេងតិចជាងម្នាក់ក្នុងចំណោម 100 នាក់ ស្លាប់ក្រោមអាយុ 5ឆ្នាំ។ ចំណែកឯនៅប្រទេសក្រីក្របំផុតមាន ក្មេងមួយភាគប្រាំ ស្លាប់ក្រោមអាយុ ៥ឆ្នាំ។ ហើយនៅខណៈដែលប្រទេសអ្នកមាន មានក្មេងតិចជាង 5ភាគរយក្នុងចំណោមក្មេងទាំងអស់ដែលមានអាយុក្រោម 5ឆ្នាំ ទទួលអាហារមិនគ្រប់គ្រាន់ នៅក្នុងប្រទេសក្រីក្រមានទៅដល់ 50 ភាគរយ។

ភាពក្រខ្សត់នៅតែកើតមាន ទោះបីជាស្ថានភាពរស់នៅរបស់មនុស្សបានកែលំអនៅក្នុងសតវត្ស

កន្លងទៅបានច្រើនជាងក្នុងប្រវត្តិសាស្ត្រទាំងមូលក៏ដោយ ក៏ទ្រព្យសម្បត្តិពិភពលោក ទំនាក់ទំនងពិភពលោក និងសមត្ថភាពនៃបច្ចេកវិទ្យាមិនទាន់មានលក្ខណៈទូលំទូលាយទេ។ ក៏ប៉ុន្តែការចែកចាយនូវផលកំរៃពិភពលោកទាំងនេះគឺមានលក្ខណៈមិនស្មើភាពដែលខុសប្លែកពីធម្មតា។ ប្រាក់ចំណូលជាមធ្យមនៅក្នុងប្រទេសអ្នកមានបំផុតចំនួន 20 ស្មើនឹង 37 ដងនៃប្រាក់ចំណូលមធ្យមនៅក្នុងប្រទេសក្រីក្របំផុតចំនួន 20 គឺគំលាតរវាងប្រទេសអ្នកមាននិងប្រទេសអ្នកក្របានកើនឡើងទ្វេដងក្នុងរយៈពេល 40 ឆ្នាំកន្លងទៅ។ ហើយបទពិសោធន៍នៅតាមតំបន់ផ្សេងៗគ្នានៅលើពិភពលោកក៏មានលក្ខណៈផ្សេងៗពីគ្នាដែរ (រូប២ សូមមើលបន្ថែមនៅតារាង 1.1 ក្នុងជំពូក 1)។ នៅក្នុងអាស៊ីបូព៌ាចំនួនប្រជាជនដែលកំពុងរស់នៅអាស្រ័យលើប្រាក់ចំណូលតិចជាង ១ដុល្លាក្នុង១ថ្ងៃបានថយចុះពីប្រហែល 420 លាននាក់មកប្រហែល 280 លាននាក់ក្នុងចន្លោះពីឆ្នាំ១៩៨៧ ដល់ឆ្នាំ១៩៩៨ ទោះបីជាបន្ទាប់ពីមានការត្រលប់ថយក្រោយនៃវិបត្តិហិរញ្ញវត្ថុ[៣] ក៏ដោយ។ រហូតមកដល់បច្ចុប្បន្ននេះ នៅក្នុងប្រទេសអាមេរិកឡាទិន អាស៊ីខាងត្បូង និងអាហ្វ្រិកអនុតំបន់សាហារ៉ា ចំនួនប្រជាជនក្រីក្រកំពុងកើនឡើង។ ហើយនៅក្នុងប្រទេសអឺរ៉ុប និងអាស៊ីកណ្ដាល នៅក្នុងសម័យអន្តរកាលឈានចូលសេដ្ឋកិច្ចទីផ្សារ ចំនួនប្រជាជនដែលកំពុងរស់នៅអាស្រ័យលើប្រាក់ចំណូលតិចជាង ១ដុល្លាក្នុងមួយថ្ងៃបានកើនឡើងច្រើនជាង ២០ដង[៤]។

ក៏មានការជឿនលឿនជាចំបងជាច្រើនផងដែរហើយនិងការត្រលប់ក្រោយដ៏ធ្ងន់ធ្ងរនៅក្នុងទំហំនៃភាពក្រីក្រដែលពុំអាចរកប្រាក់ចំនូលជាចាំបាច់បាន។ ប្រទេសឥណ្ឌាបានមើលឃើញការរីកចំរើនគួរអោយកត់សំគាល់ដែលក្មេងស្រីៗជាច្រើនបានចូលរៀន ហើយនិងនៅក្នុងរដ្ឋ Kerala ដែលជឿនលឿនជាងគេបំផុតអាយុកាលមធ្យមច្រើនជាងនៅក្នុងតំបន់ដទៃៗទៀតដែលមានកំរិតប្រាក់ចំនូលច្រើនដង (ដូចជា វ៉ាស៊ីនតោនឌីស៊ី)។

**រូប១**

**កន្លែងប្រជាជនក្រីក្ររបស់ពិភពលោកដែលកំពុងអភិវឌ្ឍរស់នៅ**

ការបែងចែកប្រជាជនដែលកំពុងរស់នៅអាស្រ័យលើប្រាក់ចំណូលតិចជាង ១ដុល្លាក្នុងមួយថ្ងៃ។ ឆ្នាំ ១៩៩៨ (១.២កោដិនាក់)




ប្រភព: ធនាគារពិភពលោកទសវត្សរ៍ឆ្នាំ២000

រហូតមកដល់បច្ចុប្បន្ននៅក្នុងប្រទេសជាច្រើនដែលជាចំនុចកណ្ដាលនៃរីករាលដាលនៃជំងឺ ហ៊ីវ/អេដស៍ នៅក្នុងទ្វីបអាហ្វ្រិក ដូចជាប្រទេស Botswana និងប្រទេស Zimbabwe មនុស្សវ័យជំទង់មួយភាគបួនត្រូវឆ្លងជំងឺនេះ។ កុមារកំព្រាដែលមានមេរោគអេដស៍កំពុងតែក្លាយជាបន្ទុកដ៏ច្រើនលើសលប់ទាំងលើយន្តការគាំទ្រជាផ្លូវការនិងជាប្រពៃណី ទាំងលើគុណប្រយោជន៍ ទាំងអស់នៅក្នុងអាយុកាលមធ្យម ព្រោះថា ពាក់កណ្ដាល

សតវត្សទី ២០ នឹងត្រូវលប់ចោលក្នុងពេលឆាប់ៗខាងមុខ។ អត្រាស្លាប់របស់ទារកដែលកំពុងប្រែប្រួលនៅលើពិភពលោក (ដូចជា អត្រាស្លាប់របស់ទារក នៅអនុតំបន់អាហ្វ្រិកសាហារ៉ាមានចំនួន ១៥ដង បើធៀបទៅនឹងប្រទេសជាច្រើនដែលមានប្រាក់ចំនូលខ្ពស់) បានផ្តល់នូវគំនិតមួយ ស្តីអំពីបទពិសោធន៍ខុសៗគ្នា ដែលមានលក្ខណៈយ៉ាងទូលំទូលាយនេះឡើង (រូប ៣)។

បទពិសោធនានាក៏មានលក្ខណៈខុសគ្នាយ៉ាងច្រើនដែរនៅឯថ្នាក់អនុជាតិ និងចំពោះស្ត្រីនិងជនជាតិភាគតិច។ តំបន់ខុសៗគ្នានៅក្នុងប្រទេសជាច្រើនមានទំហំនៃការរីកចំរើនផ្សេងៗគ្នា។ ជាឧទាហរណ៍ នៅក្នុងប្រទេសម៉ិកស៊ិកូភាពក្រីក្រសរុបបានថយចុះនៅក្នុងដើមទសវត្សរ៍ឆ្នាំ១៩៩០ ទោះបីជាថយចុះមិនសូវច្រើនក៏ដោយក៏ប៉ុន្តែវាបានកើនឡើងនៅក្នុងបណ្តាប្រទេសក្រីក្រនៅភាគអគ្នេយ៍។ វិសមភាពក៏កើតមានផងដែរ នៅក្នុងចំណោមក្រុមជាតិពន្ធនៅក្នុងប្រទេសជាច្រើន។ នៅក្នុងប្រទេសអាហ្វ្រិកមួយចំនួន អត្រាស្លាប់របស់ទារកមានកំរិតទាបជាងនៅក្នុងចំណោមក្រុមជាតិពន្ធដែលមានអំណាចខាងនយោបាយ ហើយនៅក្នុងប្រទេសអាមេរិកឡាទីនជាច្រើន ក្រុមជនអន្តោគ្រាមជាញឹកញាប់បានទទួលការសិក្សាជាមធ្យមតិចជាងបីភាគបួននៃក្រុមដែលមិនមែនជាជនអន្តោគ្រាម។ ហើយស្ត្រីនៅតែមានអត្ថប្រយោជន៍តិចជាងបុរស។ នៅអាស៊ីខាងត្បូង ស្ត្រីបានទទួលការអប់រំត្រឹមតែពាក់កណ្តាលនៃរយៈពេលសិក្សារបស់បុរស ហើយអត្រាចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅឯថ្នាក់មធ្យមសិក្សាគឺមានចំនួនតែពីរភាគបីនៃអត្រាក្មេងប្រុសប៉ុណ្ណោះ។

**រូប ២**

**តំបន់ដែលភាពក្រីក្របានថយចុះ និងតំបន់ដែលមិនមានការថយចុះ**

បំរែបំរួលនៃចំនួនមនុស្សដែលរស់នៅអាស្រ័យលើប្រាក់ចំនូលតិចជាង ១ដុល្លាក្នុងមួយថ្ងៃឆ្នាំ១៩៨៧-៩៨




ប្រភព: ធនាគារពិភពលោកទសវត្សរ៍ឆ្នាំ២០០០

**រូប៣**

**អត្រាស្លាប់របស់ទារកមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងនៅលើពិភពលោក**

អត្រាស្លាប់របស់ទារក ឆ្នាំ១៩៩៨ ក្នុង ១.០០០នាក់




ប្រភព: ធនាគារពិភពលោក ទសវត្សរ៍ឆ្នាំ២០០០

**ប្រអប់២**

**ពិភពលោកដ៏ប្រសើរមួយសំរាប់ទាំងអស់គ្នា: គោលដៅអភិវឌ្ឍន៍ អន្តរជាតិ**

① កាត់បន្ថយសមាមាត្រប្រជាជនដែលកំពុងរស់នៅក្នុងភាពក្រីក្រខ្លាំងឱ្យបានចំនួនពាក់កណ្តាលក្នុងចន្លោះពីឆ្នាំ១៩៩០ដល់២០១៥




② ចុះឈ្មោះក្មេងៗអោយបានគ្រប់គ្នានៅក្នុងសាលាបឋមសិក្សាត្រឹមឆ្នាំ២០១៥




③ លើកកំពស់សមភាពយែនឌ័រ និងផ្តល់អំណាចដល់ស្ត្រីតាមរយៈការលប់បំបាត់ចោលការប្រកាន់ភេទផ្ទុយគ្នានៅក្នុងវិស័យអប់រំកំរិតបឋមសិក្សានិងមធ្យមសិក្សាត្រឹមឆ្នាំ២០០៥




④ កាត់បន្ថយអត្រាស្លាប់របស់កុមារនិងទារកឱ្យនៅត្រឹមពីរភាគបីក្នុងចន្លោះពីឆ្នាំ១៩៩០ដល់ឆ្នាំ២០១៥




⑤ កាត់បន្ថយអនុបាតស្លាប់របស់ម្តាយអោយនៅត្រឹមបីភាគបួនក្នុងចន្លោះពីឆ្នាំ១៩៩០ដល់ឆ្នាំ២០១៥




⑥ ផ្តល់សិទ្ធិឬឱកាសសំរាប់មនុស្សទាំងអស់គ្នាដែលត្រូវការសេវា សុខភាពបន្តពូជត្រឹមឆ្នាំ២០១៥




⑦ អនុវត្តយុទ្ធសាស្ត្រជាតិសំរាប់ការអភិវឌ្ឍដែលប្រកបដោយនិរន្តរភាពត្រឹមឆ្នាំ២០០៥ ដើម្បីនឹងស្តារធនធានបរិស្ថានដែលបានបាត់បង់ឡើងវិញត្រឹមឆ្នាំ២០១៥




គោលដៅជាច្រើនសំរាប់ការអភិវឌ្ឍអន្តរជាតិឆ្លើយតបទៅនឹងបំណងប្រាថ្នា របស់មនុស្សគឺឆ្លើយតបទៅនឹងគោលដៅនៃពិភពលោកគ្មានភាពក្រីក្រនិងគ្មានទុក្ខវេទនាដែលភាពក្រីក្របង្កើតឡើង។

គោលដៅនិមួយៗក្នុងចំណោមគោលដៅទាំង ៧ ឆ្លើយតបទៅនឹងទិដ្ឋភាពមួយនៃភាពក្រីក្រ។ ពួកគេគួរតែត្រូវបានគេត្រួតពិនិត្យទាំងអស់គ្នា ពីព្រោះពួកគេ កំពុងតែពង្រឹងកំលាំងទៅវិញទៅមក។ ការចុះឈ្មោះចូលរៀនដែលមានចំនួនច្រើន ជាពិសេសចំពោះក្មេងស្រីៗ កាត់បន្ថយភាពក្រីក្រ និងអត្រាស្លាប់។ ការថែទាំសុខភាព ជាមូលដ្ឋានដែលមានលក្ខណៈល្អប្រសើរបង្កើនបាននូវការចុះឈ្មោះចូលរៀន និងកាត់បន្ថយបាននូវភាពក្រីក្រ។ ប្រជាជនក្រីក្រជាច្រើនប្រកបរបរចិញ្ចឹមជីវិតរបស់ ពួកគេដោយសារបរិស្ថាន។

ដូច្នេះចាំបាច់ត្រូវតែធ្វើអោយមានការរីកចំរើននៅលើគោលដៅនិមួយៗក្នុងចំណោមគោលដៅទាំង ៧។

នៅក្នុងទសវត្សរ៍កន្លងទៅជាមធ្យមពិភពលោកមិនទាន់បានសំរេចគោលដៅនៅឡើយទេ។ ក៏ប៉ុន្តែការរីកចំរើននៅក្នុងប្រទេសនិងតំបន់មួយចំនួនបង្ហាញអោយឃើញនូវអ្វីដែលគេអាចធ្វើបាន។ ប្រទេសចិនបានកាត់បន្ថយចំនួនប្រជាជនដែលរស់នៅក្នុងភាពក្រីក្រពី ៣៦០លាននាក់នៅក្នុងឆ្នាំ១៩៩០ មកប្រហែល ២១០លាននាក់ក្នុងឆ្នាំ១៩៩៨។ ប្រទេស Mauritius បានកាត់បន្ថយថវិកាយោធារបស់ខ្លួន ហើយនិងបានវិនិយោគយ៉ាងច្រើនទៅលើវិស័យអប់រំនិងសុខភាព។ បច្ចុប្បន្ននេះប្រជាជនរបស់ប្រទេស Mauritius ទាំងអស់មានឱកាសទទួលយកនូវអនាម័យ ៩៨ភាគរយបានប្រើប្រាស់ទឹកដែលមានសុវត្ថិភាព និង ៩៧ភាគរយ នៃការប្រសូត្រទារកត្រូវបានទទួលការថែទាំពីបុគ្គលិកសុខាភិបាលជំនាញ។ ហើយប្រទេសអាមេរិកឡាទីន ជាច្រើនបានខិតទៅរកសមភាពយែនឌ័រនៅក្នុងវិស័យអប់រំកាន់តែច្រើនឡើង។

សារលិខិតមួយបានសរសេរថា : ប្រសិនបើប្រទេសមួយចំនួនអាចធ្វើអោយមានការរីកចំរើន ដោយកាត់បន្ថយភាពក្រីក្រនៅក្នុងទំរង់ជាច្រើនរបស់ខ្លួនប្រទេសដទៃៗទៀតក៏អាចធ្វើបានដូច្នោះដែរ។ ក៏ប៉ុន្តែជំលោះទាស់ទែងកំពុងតែធ្វើអោយគុណប្រយោជន៏ដើរថយក្រោយនៅក្នុងការអភិវឌ្ឍសង្គមនៅក្នុងប្រទេសជាច្រើននៅអនុតំបន់អាហ្វ្រិកសាហារ៉ា។ ការរីករាលដាលនៃជំងឺហ៊ីវ/អេដស៍ កំពុងតែធ្វើអោយបុគ្គលម្នាក់ៗក្រុមគ្រួសារជាច្រើន និងសហគមជាច្រើននៅលើទ្វីបទាំងអស់វិនាសហិនហោច។ ហើយកំណើនសេដ្ឋិច្ចដែលមាននិរន្តរភាព (ដែលផ្អែកសំខាន់សំរាប់ការកាត់បន្ថយភាពក្រីក្ររយៈពេលវែង) នៅតែគេចចេញពីប្រទេសចំនួនពាក់កណ្តាលពិភពលោក។ ចំពោះប្រទេសច្រើនជាង ៣០ក្នុងចំណោមប្រទេសទាំងនេះ ប្រាក់ចំណូលពិតប្រាកដរបស់មនុស្សម្នាក់បានធ្លាក់ចុះអស់រយៈពេលជាង ៣៥ ឆ្នាំកន្លងទៅហើយ។ ហើយទីណាមានការរីកចំរើនគេត្រូវការអោយមានការរីករាលដាលអោយបានស្មើភាពច្រើនបន្ថែមទៀត។

គោលដៅទាំងនេះអាចសំរេចបានគឺដោយ មានការចូលរួមបញ្ចូលគ្នានៃការអនុវត្តជាលក្ខណៈអន្តរជាតិនិងជាលក្ខណៈក្នុងស្រុកដែលប្រកបដោយប្រសិទ្ធិភាព។

សំគាល់ : ទិន្នន័យនេះគឺសំរាប់តែប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យមលើកលែងតែប្រទេសទាំងឡាយណា ដែលស្ថិតនៅក្នុងយុទ្ធសាស្ត្រការពារបរិស្ថានដែលសំដៅចំពោះគ្រប់ប្រទេសទាំងអស់។

ប្រភព: មូលនិធិរូបវត្ថុអន្តរជាតិ, OECD, អង្គការសហប្រជាជាតិ និងធនាគារពិភពលោក ឆ្នាំ២០០០ (www.paris21.org/betterworld/)។

ដោយប្រឈមមុខទៅនឹងរូបភាពក្រីក្រពិភពលោក និង វិសមភាព សហគមអន្តរជាតិបានកំណត់ខ្លួនឯងនូវ គោលដៅជាច្រើនសំរាប់ឆ្នាំដំបូង១នៃសតវត្សនេះ ដោយឈរលើមូលដ្ឋាននៃការពិភាក្សានានានៅឯសន្និសិទអង្គការសហប្រជាជាតិនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ (ប្រអប់ ២)។ គោលដៅអភិវឌ្ឍន៍អន្តរជាតិទាំងនេះភាគច្រើនសំរាប់ឆ្នាំ២០១៥ រួមបញ្ចូលទាំងការកាត់បន្ថយភាពក្រីក្រលើប្រាក់ចំនូលនិងភាពខ្វះខាតធនធានមនុស្សនៅក្នុងផ្នែកសំខាន់១ជាច្រើន (ចំនុចគោល១ មានបង្ហាញនៅក្នុងរូបសំរាប់ឆ្នាំ១៩៩០):

- កាត់បន្ថយសមមាត្រប្រជាជនដែលកំពុងរស់នៅក្នុងភាពក្រីក្រខ្លាំងលើប្រាក់ចំណូលអោយបានពាក់កណ្តាល (ការរស់នៅអាស្រ័យលើប្រាក់ចំនូលតិចជាង ១ដុល្លាក្នុងមួយថ្ងៃ)។
- ធានាដល់ការអប់រំថ្នាក់បឋមសិក្សាដែលមានលក្ខណៈជាសកល។
- លប់បំបាត់ចោលនូវការប្រកាន់ភេទផ្ទុយគ្នាក្នុងវិស័យអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សា (ត្រឹមឆ្នាំ២០០៥)។
- កាត់បន្ថយអត្រាស្លាប់របស់ទារក និងកុមារឱ្យនៅត្រឹមពីរភាគបី។
- កាត់បន្ថយអត្រាស្លាប់របស់មាតាឱ្យនៅត្រឹមបីភាគបួន។
- ធានាដល់ឱកាសទទួលយកនូវសេវាកម្មសុខភាពបន្តពូជដែលមានលក្ខណៈជាសកល។
- អនុវត្តយុទ្ធសាស្ត្រថ្នាក់ជាតិសំរាប់ការអភិវឌ្ឍដែលប្រកបដោយនិរន្តរភាព នៅក្នុងគ្រប់ប្រទេសទាំងអស់ត្រឹមឆ្នាំ២០០៥ ដើម្បីនឹងស្តារឡើងវិញនូវការបាត់បង់ធនធានបរិស្ថានត្រឹមឆ្នាំ២០១៥។

គោលដៅទាំងនេះនឹងត្រូវបានសំរេចនៅក្នុងពិភពលោកមួយដែលចំនួនប្រជាជននៅលើពិភពលោកនឹងកើនឡើងប្រមាណ ២កោដិនាក់ក្នុងរយៈពេល ២៥ឆ្នាំខាងមុខ ដែលក្នុងនោះមាន ៩៧ភាគរយកើនឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍនានា។ ការសិក្សាជាច្រើនអំពីកិច្ចការដែលត្រូវធ្វើដើម្បីសំរេចគោលដៅទាំងនេះ បង្ហាញអោយឃើញពីទំហំនៃបញ្ហាប្រឈម។ ជាឧទាហរណ៍ ការកាត់បន្ថយនូវភាពខ្វះខាតប្រាក់ចំនូលអោយបានចំនួនពាក់កណ្តាលក្នុងចន្លោះឆ្នាំ១៩៩០ ដល់ឆ្នាំ២០១៥ នឹងទាមទារអោយអត្រាសមាសថយចុះចំនួន ២,៧ភាគរយក្នុងមួយឆ្នាំក្នុងកំឡុងពេល ២៥ឆ្នាំនោះ។ ការប៉ាន់ស្មានចុងក្រោយរបស់ធនាគារពិភពលោកចង្អុលបង្ហាញអោយឃើញពីការថយចុះចំនួនប្រហែល ១,៧ភាគរយក្នុងមួយឆ្នាំ ក្នុងចន្លោះពីឆ្នាំ១៩៩០ដល់ឆ្នាំ១៩៩៨។ ការរីកចំរើនជាច្រើនដែលមានល្បឿនយឺតដែលត្រូវបានគេធ្វើអង្កេតនៅក្នុងតំបន់មួយចំនួនគឺដោយសារតែមានកំណើនទាបរឺអវិជ្ជមាន។ នៅក្នុងករណីខ្លះដែលកំពុងកើតមានវិសមភាពបានបង្កើននូវឥទ្ធិពលនេះ។ ជាពិសេសបញ្ហានេះកើតមានឡើងនៅក្នុងបណ្តាប្រទេសអតីតសហភាពសូវៀត។ ល្បឿននៃការចុះឈ្មោះចូលរៀននាពេលបច្ចុប្បន្នមើលទៅមិនទំនងជានាំមកនូវការអប់រំថ្នាក់បឋមសិក្សាដែលមានលក្ខណៈជាសកលនោះទេ ជាពិសេសនៅក្នុងអនុតំបន់អាហ្វ្រិកសាហារ៉ា។ ការកាត់បន្ថយអត្រាស្លាប់របស់ទារកអោយនៅត្រឹមពីរ

ភាគបីនៅក្នុងចន្លោះពីឆ្នាំ១៩៩០ដល់ឆ្នាំ២០១៥ នឹងទាមទារអោយមានការថយចុះចំនួន ៣០ភាគរយ ក្នុងចន្លោះពីឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩៨ ដែលចំនួននេះច្រើនជាងប្រទេសកំពុងអភិវឌ្ឍចំនួន ១០ ភាគរយបានទទួល។ នៅក្នុងតំបន់មួយចំនួននៃអនុតំបន់អាហ្វ្រិកសាហារ៉ា អត្រាស្លាប់របស់ទារកមានការកើនឡើងយ៉ាងពិតប្រាកដដែលមួយផ្នែកបណ្តាលមកពីការរីករាលដាលនៃជំងឺអេដស៍។ ហើយអនុបាតស្លាប់របស់មាតាកំពុងតែថយចុះយឺតពេកដែលមិនអាចឆ្លើយតបទៅនឹងគោលដៅទាំងនេះបាន។

ការសំរេចបាននូវគោលដៅអភិវឌ្ឍអន្តរជាតិទាំងនេះនឹងទាមទារនូវការងារជាច្រើនដើម្បីជំរុញឱ្យមានកំណើនសេដ្ឋកិច្ចនិងកាត់បន្ថយវិសមភាពនៃប្រាក់ចំនូល ក៏ប៉ុន្តែសូម្បីតែកំណើនសមភាពក៏នឹងមិនទាន់គ្រប់គ្រាន់ដើម្បីសំរេចគោលដៅទាំងឡាយសំរាប់វិស័យអប់រំនិងសុខាភិបាលដែរ។ ការកាត់បន្ថយអត្រាស្លាប់របស់កុមារនិងទារកអោយនៅត្រឹមពីរភាគបីគឺត្រូវពឹងផ្អែកទៅលើការបញ្ឈប់ការរីករាលដាលនៃជំងឺហ៊ីវ/អេដស៍ ដោយបង្កើនសមត្ថភាពនៃប្រព័ន្ធសុខាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍទាំងឡាយ ដើម្បីផ្តល់នូវសេវាសុខាភិបាលអោយបានច្រើនបន្ថែមទៀត ហើយ និងធានាថា ភាពជឿនលឿននៃបច្ចេកវិទ្យានៅក្នុងវិស័យពេទ្យគ្របដណ្តប់គ្រប់ទីកន្លែងដើម្បីផ្តល់អត្ថប្រយោជន៏ដល់ពិភពលោកដែលកំពុងអភិវឌ្ឍ[៥]។ ហើយការឆ្លើយតបចំពោះគោលដៅសមភាពយែនឌ័រនៅក្នុងវិស័យអប់រំនឹងទាមទារអោយមានវិធានការនយោបាយជាក់លាក់ដើម្បីដោះស្រាយឧបសគ្គវប្បធម៌សង្គម និងសេដ្ឋកិច្ចដែលរារាំងក្មេងស្រីៗមិនអោយចូលសាលារៀន[៦]។ លើសពីនេះទៅទៀតការងារដើម្បីធានាដល់និរន្តរភាពបរិស្ថានដ៏ធំធេងនឹងមានសារសំខាន់ក្នុងការបង្កើនទ្រព្យសម្បត្តិដែលអ្នកក្រីក្រអាចទទួលយកបាននិងនៅក្នុងការកាត់បន្ថយការកើតមានឡើងនៃភាពក្រីក្រសំរាប់រយៈពេលវែង[៧]។ សកម្មភាពការងារទាំងនេះនឹងធ្វើអន្តរកម្មដើម្បីរុញច្រានអោយបានសំរេចគោលដៅទាំងនេះ។ ហេតុនេះ កាលណាមានសេចក្តីត្រូវការចាំបាច់កាន់តែច្រើន គេក៏ត្រូវការយុទ្ធសាស្ត្រដ៏ទូលំទូលាយបន្ថែមទៀតដែរ ដើម្បីប្រយុទ្ធនិងភាពក្រីក្រ។

## យុទ្ធសាស្ត្រសំរាប់ការកាត់បន្ថយភាពក្រីក្រ

របៀបដោះស្រាយក្នុងការកាត់បន្ថយភាពក្រីក្របានវិវត្តន៏អស់រយៈពេលជាង ៥០ឆ្នាំកន្លងទៅហើយ ដើម្បីឆ្លើយតបទៅនឹងការស៊ីជំរៅលើការយល់ដឹងអំពីភាពស្មុគ្រស្មាញនៃការអភិវឌ្ឍ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ និងទសវត្សរ៍ឆ្នាំ១៩៦០ យុទ្ធសាស្ត្រជាច្រើនបានចាត់ទុកការវិនិយោគទ្រង់ទ្រាយធំៗលើហេដ្ឋារចនាសម្ព័ន្ធនិងមូលធនរូបវន្តថា ជាមធ្យោបាយសំខាន់សំរាប់ការអភិវឌ្ឍ។

ការយល់ដឹងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ បានបង្ហាញថា មូលធនរូបវន្តនោះមិនទាន់គ្រប់គ្រាន់ទេ ហើយថា យ៉ាងហោចណាស់កត្តាសំខាន់ដែលត្រូវយកចិត្តទុកដាក់នោះគឺវិស័យអប់រំនិងសុខាភិបាល។ របាយការណ៍អភិវឌ្ឍន៏ពិភពលោកឆ្នាំ១៩៨០ បានបង្ហាញឱ្យឃើញនូវការយល់ដឹងនេះ ហើយនិងបានលើកហេតុផលថាការកែលំអក្នុងវិស័យអប់រំ និងសុខាភិបាលមិនមែន

មានសារសំខាន់ត្រឹមតែចំពោះសិទ្ធិផ្ទាល់ខ្លួនប៉ុណ្ណោះទេ ក៏ប៉ុន្តែ ថែមទាំងជួយជំរុញអោយមានកំណើនប្រាក់ចំណូលដល់ប្រជាជនក្រីក្រផងដែរ ។

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨0 គេបានមើលឃើញអំពីការផ្លាស់ប្តូរមួយទៀតដោយសង្កត់ធ្ងន់ទៅលើវិបត្តិបំណុល និងដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ហើយនិងបទពិសោធន៍ផ្ទុយគ្នាដែលកើតមាននៅអាស៊ីបូព៌ានិងអាមេរិកឡាទីន អាស៊ីខាងត្បូង និងអនុតំបន់អាហ្វ្រិកសាហារ៉ា ។ ការសង្កត់ធ្ងន់នេះត្រូវបានកំណត់លើការកែលំអការគ្រប់គ្រងសេដ្ឋកិច្ច និងរួមបញ្ចូលទាំងកំលាំងទីផ្សារ ។ របាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ១៩៩0 : ភាពក្រីក្រទាមទារនូវយុទ្ធសាស្ត្រមួយដែលមានពីរផ្នែកគឺៈ ជំរុញអោយមានកំណើនអតិពលកម្មតាមរយៈការបើកចំហរសេដ្ឋកិច្ចនិងការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់សេវាកម្មជាមូលដ្ឋានដល់ប្រជាជនក្រីក្រអោយទទួលបាននូវការអប់រំ និងសុខាភិបាល ។

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩0 អភិបាលកិច្ច និងស្ថាប័នបានឈានទៅដល់ដំណាក់កាលកណ្តាលហើយ ដូចជា ការដោះស្រាយបញ្ហាឈឺចាប់នានានៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។ របាយការណ៍នេះធ្វើឡើងដោយផ្អែកលើយុទ្ធសាស្ត្រមុនៗ ដែលទាក់ទងទៅនឹងភស្តុតាងនិងបទពិសោធន៍បន្ថែមលើគ្នាពីទសវត្សរ៍កន្លងមក ហើយដែលទាក់ទងទៅនឹងបរិបទសកលលោកដែលមានការផ្លាស់ប្តូរ ។ គេស្នើសុំអោយមានយុទ្ធសាស្ត្រមួយសំរាប់ប្រយុទ្ធនឹងភាពក្រីក្រតាមវិធីសាស្ត្របីយ៉ាង ជំរុញកាលានុវត្តភាព ជួយសំរួលការផ្តល់អំណាច និងលើកកំពស់សន្តិសុខ ។

- *ការជំរុញឱ្យមានកាលានុវត្តភាព ។* ជនក្រីក្រយកចិត្តទុកដាក់ ព្រមគ្នាទៅលើសារៈសំខាន់នៃឱកាសជាសំភារៈ ។ ប្រការនេះ មានន័យថា ការងារឥណទាន ផ្លូវថ្នល់ អគ្គសនី ទីផ្សារសំរាប់ផលិតផលរបស់គាត់ និងសាលារៀន ទឹកអនាម័យ និងសេវាសុខភាព និងជំនាញចាំបាច់សំរាប់ធ្វើការងារ ។ កំណើនសេដ្ឋកិច្ចជារួមមានសារៈសំខាន់ណាស់ សំរាប់បង្កើតឱ្យមានឱកាស ។ ដូចគ្នានឹងទំរង់ ឬ គុណភាពនៃ កំណើនដែរ ។ កំណែទំរង់ទីផ្សារ អាចជាការសំខាន់ផងដែរក្នុងការពង្រីកទីផ្សារសំរាប់ជនក្រីក្រ ប៉ុន្តែ កំណែទំរង់នោះ ត្រូវឆ្លុះបញ្ចាំងពីល័ក្ខខ័ណ្ឌស្ថាប័ន និងរចនាសម្ព័ន្ធនៅមូលដ្ឋាន ។ ត្រូវមានយន្តការសំរាប់បង្កើតឱកាសថ្មី និង សងការខូចខាតដល់អ្នកបាត់បង់នៅក្នុងពេលអន្តរកាល ។នៅក្នុងសង្គមដែលមានវិសមភាពខ្ពស់ សមធមិកាន់តែទូលំទូលាយ មានសារៈសំខាន់ជាពិសេសសំរាប់ឱ្យមានការរីកចំរើនយ៉ាងរហ័សនៅក្នុងការកាត់បន្ថយភាពក្រីក្រ ។ ប្រការនេះ ទាមទារឱ្យមានសកម្ម-ភាពរបស់រដ្ឋ ដើម្បីគាំទ្រការកសាងមនុស្ស ដី និងទ្រព្យសម្បត្តិហេដ្ឋារចនាសម្ព័ន្ធដែលជនក្រីក្រ ធ្វើជាម្ចាស់បាន ឬ ជនក្រីក្រ អាចប្រើប្រាសបាន ។
- *សំរបសំរួលឱ្យមានការផ្តល់អំណាច ។* ជំរើស និងការអនុវត្តសកម្មភាពសាធារណៈ ដែលឆ្លើយតបទៅនឹងតំរូវការរបស់ជនក្រីក្រ អាស្រ័យទៅលើទំនាក់ទំនងនយោបាយ សង្គម និង ដំណើរការស្ថាប័នផ្សេងទៀត ។ លទ្ធភាពទទួលបានឱកាសទីផ្សារ និង សេវាសាធារណៈ ជាញឹកញាប់ ត្រូវ

ទទួលរងឥទ្ធិពលយ៉ាងខ្លាំងក្លាដោយរដ្ឋ និងស្ថាប័នសង្គម ដែលត្រូវតែមានការឆ្លើយតប និង មានការទទួលខុសត្រូវចំពោះជនក្រីក្រ ។ ការទទួលបានការប្រើប្រាស់ និង ការទទួលខុសត្រូវ ជាសមាសធាតុនយោបាយយ៉ាងសំខាន់ ហើយទាមទារឱ្យមានការសហការនៅក្នុងចំណោមជនក្រីក្រ មនុស្សថ្នាក់កណ្តាល និង ក្រុមផ្សេងទៀតនៅក្នុងសង្គម ។ ការសហការយ៉ាងសកម្ម អាចត្រូវបានសំរបសំរួលយ៉ាងធំធេងតាមរយៈការកែប្រែអភិ-បាលកិច្ច ដែលធ្វើឱ្យរដ្ឋបាលសាធារណៈ ស្ថាប័នច្បាប់ និង ការផ្តល់សេវាសាធារណៈ កាន់តែមានប្រសិទ្ធិភាព និង មានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋទាំងអស់ និង តាមរយៈការពង្រឹងការចូលរួមរបស់ជនក្រីក្រនៅក្នុងដំណើរការនយោបាយ និង ការធ្វើសេចក្តីសំរេចចិត្តនៅមូលដ្ឋាន ។ អ្វីដែលសំខាន់ផងដែរនោះ គឺការលុបបំបាត់រនាំងសង្គម និង ស្ថាប័នដែលបណ្តាលមកពីភាពខុសគ្នាដោយសារភេទ ជាតិ សាសន៍ និង ឋានៈនៅក្នុងសង្គម។ ស្ថាប័នសមស្រប និង ដែលមានការឆ្លើយតប មិនគ្រាន់តែមានសារៈសំខាន់ចំពោះការផ្តល់ផលប្រយោជន៍ ដល់ជនក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសារៈសំខាន់ជាសារវ័ន្តចំពោះដំណើរការរីកចំរើនជារួម។

- *ការលើកកំពស់សន្តិសុខ* ។ ការកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច គ្រោះធម្មជាតិ សុខ-ភាពមិនល្អ ពិការភាព និង អំពើហិង្សាផ្ទាល់ខ្លួន គឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងការលើកកំពស់សុខុមាលភាព និង ជំរុញការវិនិយោគលើទុនមនុស្ស និង សកម្មភាពការប្រថុយនឹងគ្រោះថ្នាក់ខ្ពស់ នាំឱ្យទទួលបានផលច្រើន ។ ប្រការនេះទាមទារឱ្យមានសកម្មភាពយ៉ាងមានប្រសិទ្ធិភាពរបស់ជាតិ ដើម្បីគ្រប់គ្រងគ្រោះថ្នាក់ផ្នែកសេដ្ឋកិច្ចទាំងមូល និង យន្តការយ៉ាងមានប្រសិទ្ធិភាពដើម្បីកាត់បន្ថយគ្រោះថ្នាក់ដែលជនក្រីក្រជួបប្រទះ រួមមានគ្រោះថ្នាក់ទាក់ទងទៅនឹងសុខភាព និង អាកាសធាតុ ។ វាក៏ទាមទារឱ្យមានផងដែរនូវការកសាងទ្រព្យសម្បត្តិរបស់ជនក្រីក្រ សកម្មភាពចំរុះនៅតាមគ្រួសារ និងការផ្តល់យន្តការធានារ៉ាប់រងមួយចំនួន ដើម្បីទប់ទល់នឹងឥទ្ធិពលអវិជ្ជមាន ដូចជាកម្មវិធីការងារសាធារណៈ ការស្នាក់នៅក្នុងសាលារៀន និង ការធានារ៉ាប់រងសុខភាព ។

ចំណុចទាំងបីខាងលើនេះ គ្មានចំណុចណាសំខាន់ ជាងចំណុចណាទេ ។ សមាសធាតុទាំងបីនេះបំពេញ បន្ថែមឱ្យគ្នាទៅវិញទៅមកយ៉ាងជ្រាលជ្រៅ ។ ផ្នែក ទីមួយ ៧ នៃយុទ្ធសាស្ត្រនេះ មានការប៉ះពាល់ទៅលើបុព្វហេតុនៃភាពក្រីក្រ ដែលត្រូវដោះស្រាយដោយ ចំណុចពីរទៀត ។ ឧទាហរណ៍ ការជំរុញឱ្យមានឱកាស តាមរយៈការប្រើប្រាស់ទ្រព្យសម្បត្តិ និង ទីផ្សារ បង្កើនឯករាជ្យភាពរបស់ជនក្រីក្រ ដូច្នេះ ផ្តល់អំណាច ឱ្យគាត់ តាមរយៈការពង្រឹងជំហរតវ៉ា របស់គាត់នៅក្នុង រដ្ឋ និង សង្គម។ វាក៏លើកកំពស់សន្តិសុខផងដែរ ដោយហេតុថា ទ្រព្យសម្បត្តិគ្រប់គ្រាន់ ជួយសំរាល ឥទ្ធិពលអវិជ្ជមាន ។ ដូចគ្នានេះដែរ ការពង្រឹងស្ថាប័ន ប្រជាធិបតេយ្យ និង ការផ្តល់អំណាចដល់ស្ត្រី និង ក្រុមជាតិសាសន៍ដែលបាត់បង់

ឱកាស តាមរយៈការ លុបបំបាត់ការរើសអើងតាមផ្លូវច្បាប់មកលើអ្នកទាំងនោះ ពង្រីកនូវឱកាសផ្នែកសេដ្ឋកិច្ចសំរាប់ជនក្រីក្រ និង ជននៅក្រៅសង្គម ។ ការពង្រឹងអង្គការរបស់ជនក្រីក្រ អាចជួយធានាដល់ការផ្តល់សេវា និង ជំរើសផ្នែក គោលនយោបាយដែលឆ្លើយតបចំពោះសេចក្តីត្រូវការ របស់ជនក្រីក្រ និង អាចកាត់បន្ថយអំពើពុករលួយ និង ការធ្វើសកម្មភាពទៅតាមអំពើចិត្តរបស់រដ្ឋផងដែរ ។ ហើយប្រសិនបើជនក្រីក្រ ធ្វើការងារកាន់តែច្រើននៅ ក្នុងការពិនិត្យតាមដាន និង ត្រួតពិនិត្យការផ្តល់សេវា សង្គមនៅមូលដ្ឋាន នោះការចំណាយសាធារណៈ ហាក់ដូចជាជួយជនក្រីក្របានកាន់តែច្រើននៅក្នុងអំឡុងពេលមានវិបត្តិ ។ ជាចុងបញ្ចប់ ការជួយជនក្រីក្រឱ្យទប់ទល់នឹងវិបត្តិ និង គ្រប់គ្រងគ្រោះថ្នាក់ ធ្វើឱ្យគាត់ស្ថិតនៅក្នុងទីតាំងកាន់តែប្រសើរ ដើម្បីទទួលបានផលប្រយោជន៍ពីឱកាសទីផ្សារដែលកើតឡើងថ្មី ។ ហេតុនេះហើយទើបរបាយការណ៍នេះ គាំទ្រវិធីសាស្ត្រដ៏ទូលំទូលាយដើម្បីប្រយុទ្ធប្រឆាំងភាពក្រីក្រ ។

## ពីយុទ្ធសាស្ត្រទៅជាសកម្មភាព

គ្មានពុម្ពគំរូសាមញ្ញ ពុម្ពគំរូជាសកលសំរាប់អនុវត្តយុទ្ធសាស្ត្រនេះទេ ។ ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវរៀបចំគោលនយោបាយ ចំរុះរបស់ខ្លួនផ្ទាល់ដើម្បីកាត់បន្ថយភាពក្រីក្រ ដែលឆ្លុះបញ្ចាំងអាទិភាពជាតិនិងតថភាពនៅមូលដ្ឋាន ។ ជំរើស នឹងអាស្រ័យលើបរិបទសេដ្ឋកិច្ច នយោបាយសង្គម រចនាសម្ព័ន្ធ និង វប្បធម៌របស់ ប្រទេស និង សហគមន៍នីមួយៗ ។

ក្នុងពេលដែលរបាយការណ៍នេះ លើកឡើងពីវិធីសាស្ត្រកាន់តែទូលំទូលាយ អាទិភាពនឹងត្រូវកំណត់នៅ ក្នុងករណីនីមួយ ៗ ដោយផ្អែកទៅលើធនធាន និង អ្វីដែលអាចធ្វើទៅបាននៅក្នុងស្ថាប័ន ។ ការរីកចំរើននៅក្នុងការកាត់បន្ថយទិដ្ឋភាពមួយចំនួននៃការបាត់បង់ សិទ្ធិអំណាច អាចប្រព្រឹត្តិទៅបាន ទោះបីជាទិដ្ឋភាពផ្សេងទៀតនៅតែគ្មានការប្រែប្រួលក្តី ។ ឧទាហរណ៍ យុទ្ធនាការលុបបំបាត់ការខ្សោះទឹកក្នុងខ្លួនដែលមាន តំលៃថោក អាចកាត់បន្ថយមរណភាពទារកទោះបីជា ប្រាក់ចំណូលរបស់ជនក្រីក្រ មិនមានការប្រែប្រួលក្តី[៨] ។ ប៉ុន្តែជាទូទៅចាំបាច់ត្រូវមានសកម្មភាពនៅក្នុងកត្តាបី យ៉ាងគឺ ឱកាស ការផ្តល់សិទ្ធិអំណាច និងសន្តិសុខដោយសារកត្តាទាំងបីនេះ មានការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ។

សកម្មភាពរបស់ប្រទេសអភិវឌ្ឍន៍ និងអង្គការពហុភាគីមានសារៈសំខាន់ណាស់ ។ កំលាំងជាច្រើនដែលប៉ះពាល់មកលើជីវិតរបស់ជនក្រីក្រស្ថិតនៅហួសពីឥទ្ធិពល ឬ ការត្រួតត្រារបស់វា ។ ប្រទេសកំពុងអភិវឌ្ឍន៍មិនអាចបង្កើតឱ្យមានស្ថេរភាពហិរញ្ញវត្ថុអន្តរជាតិ ការរីកចំរើនជាខ្លាំងនៅក្នុងការស្រាវជ្រាវផ្នែកសុខភាព និង កសិកម្ម និង ឱកាសពាណិជ្ជកម្មអន្តរជាតិដោយខ្លួនឯងបានទេ ។ សកម្មភាពរបស់ សហគមន៍អន្តរជាតិ និង កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅតែជាការ[៩] សំខាន់ ។

ខាងក្រោមនេះ គឺជាវិស័យដែលទាមទារឱ្យមានសកម្មភាពដោយជាតិ និង អន្តរជាតិ ។

### *ឱកាស*

គោលនយោបាយ និង ស្ថាប័នស្នូល សំរាប់បង្កើតឱ្យមានឱកាសច្រើនថែមទៀត ពាក់ព័ន្ធទៅនឹងសកម្មភាពដែលបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ដើម្បីជំរុញការរីកចំរើនជារួម ធ្វើឱ្យទីផ្សារដំណើរការសំរាប់ជនក្រីក្រ និងកសាងទ្រព្យសម្បត្តិរបស់គាត់ រួមមានការដោះស្រាយវិសមភាពធ្ងន់ធ្ងរនៅក្នុងការបែងចែក ជំនួយ ដូចជានៅក្នុងការអប់រំ ។

*ការជំរុញការវិនិយោគឯកជនយ៉ាងមានប្រសិទ្ធិភាព* ។ ការវិនិយោគ និង បច្ចេកវិទ្យាថ្មី គឺជាកំលាំងចលករយ៉ាងសំខាន់ចំពោះការរីកចំរើននៅក្នុងការងារ និង ប្រាក់ចំណូលពីកំលាំងពលកម្ម ។ ការជំរុញការវិនិយោគឯកជន ទាមទារឱ្យមានការកាត់បន្ថយគ្រោះថ្នាក់ចំពោះអ្នកវិនិយោគឯនជន តាមរយៈគោលនយោបាយហិរញ្ញវត្ថុ និង រូបិយវត្ថុ ដែលមានស្ថេរភាព របបវិនិយោគដែលមានស្ថេរភាព ប្រព័ន្ធហិរញ្ញវត្ថុសមស្រប និង បរិយាកាសធ្វើអាជីវកម្មច្បាស់លាស់ និង មានតម្លាភាព ។ ប៉ុន្តែវាក៏ពាក់ព័ន្ធទៅនឹងការធានាឱ្យមានការគ្រប់គ្រងដោយច្បាប់ និងការចាត់វិធានការប្រយុទ្ធប្រឆាំងអំពើពុករលួយ គឺការដោះស្រាយបរិយាកាសអាជីវកម្មដែលផ្អែកទៅលើប្រាក់ចំណូល ការឧបត្ថម្ភធនដល់អ្នកវិនិយោគទ្រង់ទ្រាយធំ ការចុះកិច្ចសន្យាពិសេស និង ការធ្វើអាជីវកម្មផ្តាច់មុខដែលបានអនុគ្រោះ ។

នៅពេលខ្លះ វិធានការពិសេស មានសារៈសំខាន់ជាសារវន្តដើម្បីធានាឱ្យបានថា សហគ្រាសធុនតូច និង អាជីវកម្មតូចតាច ដែលងាយទទួលរងគ្រោះដោយសារពួករដ្ឋអំណាច និង ការទិញអភ័យឯកសិទ្ធិដោយពួកអ្នកដែលមានខ្សែបណ្តាញរឹងមាំ អាចចូលរួមនៅក្នុងទីផ្សារបានយ៉ាងមានប្រសិទ្ធិភាព ។ វិធានការទាំងនេះរួមមានការធានាឱ្យមានការប្រើប្រាស់ឥណទាន តាមរយៈការជំរុញឱ្យមានភាពស៊ីជំរៅផ្នែកហិរញ្ញវត្ថុ និង ការកាត់បន្ថយប្រភពនៃបរាជ័យផ្នែកទីផ្សារ ការកាត់បន្ថយការចំណាយនៅក្នុងការធ្វើជំនួញសំរាប់ទីផ្សារនាំចេញ តាមរយៈការពង្រីកលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាអ៊ិនធើណេត ការរៀបចំការតាំងពិពណ៌ផលិតផលនាំចេញ និង ការផ្តល់ការបណ្តុះបណ្តាលក្នុងការអនុវត្តធ្វើអាជីវកម្មទំនើប និង ការកកសាងផ្លូវគមនាគមន៍ដើម្បីកាត់បន្ថយរនាំងរូបវ័ន្ត ។ ការបង្កើតបរិយាកាសធ្វើអាជីវកម្មសមស្របសំរាប់គ្រួសារក្រីក្រ និង ក្រុមហ៊ុនតូចតាច ក៏អាចពាក់ព័ន្ធទៅនឹងការកែប្រែបទបញ្ញត្តិ និង ការកែទំរង់ស្ថាប័នដែលមានការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ឧទាហរណ៍ ការកាត់បន្ថយការរឹតត្បិតមកលើវិស័យក្រៅផ្លូវការ ជាពិសេសវិស័យដែលមានការប៉ះពាល់មកលើស្ត្រី និង ការដោះស្រាយការកាន់កាប់ដីធ្លី ឬ ការចុះឈ្មោះមិនគ្រប់គ្រាន់ដែលរារាំងដល់ការវិនិយោគតូចតាច ។

ការវិនិយោគឯកជន នឹងត្រូវបំពេញបន្ថែមដោយការវិនិយោគសាធារណៈ ដើម្បីលើកកំពស់ការប្រកួតប្រជែង និង បង្កើតឱកាសទីផ្សារថ្មី ។ អ្វីដែលសំខាន់ជាពិសេសនោះ គឺការវិនិយោគសាធារណៈបំពេញបន្ថែមនៅក្នុងការពង្រីកហេដ្ឋារចនាសម្ព័ន្ធ និង ការប្រាស្រ័យទាក់ទង និង កែលំអជំនាញរបស់កំលាំងពលកម្ម ។

*ការពង្រីកទៅក្នុងទីផ្សារអន្តរជាតិ* ។ ទីផ្សារអន្តរជាតិ ផ្តល់ឱកាសយ៉ាងធំធេងដល់ការរីកចំរើកលើការងារ និង ប្រាក់ចំណូល គឺនៅក្នុងកសិកម្ម ឧស្សាហកម្ម និង សេវា ។ ប្រទេសទាំងអស់ដែលបានកាត់បន្ថយ

យ៉ាងច្រើនលើភាពក្រីក្រផ្នែកប្រាក់ចំណូល បានប្រើប្រាស់ពាណិជ្ជកម្មអន្តរជាតិ ។ ប៉ុន្តែការបើកឱ្យមានពាណិជ្ជកម្ម អាចបង្កើតឱ្យមានអ្នកចាញ់ និង អ្នកឈ្នះ ហើយវាផ្តល់ផលប្រយោជន៍យ៉ាងច្រើនតែនៅក្នុងប្រទេសណាដែលមានហេដ្ឋារចនាសម្ព័ន្ធ និង ស្ថាប័នដើម្បីគាំទ្រការឆ្លើយតបទៅនឹងការផ្គត់ផ្គង់ខ្លាំងក្លា ។ ដូច្នេះការបើកចំហនេះ ត្រូវរចនាឱ្យបានល្អ ដោយមានការយកចិត្តទុកដាក់ជាពិសេសទៅលើស្ថានភាពជាក់លាក់របស់ប្រទេស និង ឧបសគ្គផ្នែកស្ថាប័ន និង ឧបសគ្គផ្សេងទៀត ។ គោលនយោបាយ គួរជំរុញឱ្យមាន ការបង្កើតការងារ និង គ្រប់គ្រងការបំផ្លាញការងារ ។ សេរីភាពដែលកាន់តែគាំទ្រជនក្រីក្រ មិនមែនកាន់តែមានការយឺតយ៉ាវទេ ។ ការវិវត្តយ៉ាងលឿន អាចបង្កើតឱកាសកាន់តែច្រើនសំរាប់ជនក្រីក្រ ។ ហើយគោលនយោបាយច្បាស់លាស់ គួរតែជួយដល់ជនក្រីក្រនៅក្នុងដំណាក់កាលអន្តរកាល ដូចដែលធ្លាប់អនុវត្តក្នុងការផ្តល់ជំនួយដល់អ្នកផលិតពោតតូចតាចនៅប្រទេសម៉ិចស៊ិកូនៅពេលមានកិច្ចព្រមព្រៀងពាណិជ្ជកម្មដោយសេរីនៅអាមេរិកខាងជើង (NAFTA) ។

ការបើកគណនេយ្យទុន ត្រូវតែមានការគ្រប់គ្រងប្រកបដោយភាពវៃឆ្លាត គឺជាជំហានជាមួយនឹងការអភិវឌ្ឍផ្នែកហិរញ្ញវត្ថុនៅក្នុងស្រុក ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃបំរែបំរួលខ្ពស់នៅក្នុងចរាចរទុន ។ ការវិនិយោគដោយផ្ទាល់រយៈពេលវែង អាចនាំមកនូវឥទ្ធិពលពីខាងក្រៅជាវិជ្ជមាន ដូចជា ការផ្ទេរចំណេះដឹង ប៉ុន្តែចរាចររយៈពេលវែងអាចនាំមកនូវឥទ្ធិពលពីខាងក្រៅជាអវិជ្ជមាន ជាពិសេស ងាយនឹងមានការប្រែប្រួល ។ គោលនយោបាយត្រូវដោះស្រាយបញ្ហាទាំងនេះ ដោយឡែកពីគ្នា ។

*ការកសាងទ្រព្យសម្បត្តិរបស់ជនក្រីក្រ* ។ ការបង្កើតទ្រព្យជាមនុស្ស សំភារៈ ធម្មជាតិ និង ហិរញ្ញវត្ថុ ដែលជនក្រីក្រធ្វើជាម្ចាស់ ឬ អាចប្រើប្រាស់បាន ទាមទារឱ្យមានសកម្មភាពលើវិស័យចំនួនបី ។ ទីមួយ បង្កើនការយកចិត្តទុកដាក់នៃការចំណាយសាធារណៈមកលើជនក្រីក្រ ការពង្រីកការផ្តល់សេវាសង្គម និង សេដ្ឋកិច្ចជាមូលដ្ឋាន និង កាត់បន្ថយការរឹតត្បិតមកលើតំរូវការ (ឧទាហរណ៍ តាមរយៈការផ្តល់អាហារូបករណ៍ដល់កុមារក្រីក្រ) ។ ទីពីរ ធានាការផ្តល់សេវាដែលមានគុណភាពល្អ តាមរយៈ សកម្មភាពនៅក្នុងស្ថាប័នដែលពាក់ព័ន្ធទៅនឹងអភិបាលកិច្ចត្រឹមត្រូវ និង ការប្រើប្រាស់ទីផ្សារ និង ទីភ្នាក់ងារចំរុះ ។ ប្រការនេះ អាចសំដៅទៅលើការកែទំរង់ការសេវាសាធារណៈ ដូចជាការអប់រំ ឬ ឯកជនភាវូបនីយកម្មដែលធានាដល់ការពង្រីកសេវាដល់ជនក្រីក្រ ដូចជា ទឹក និង អនាម័យនៅទីប្រជុំជន ។ ទីបី ធានាឱ្យមានការចូលរួមរបស់សហគមន៍ និង គ្រួសារក្រីក្រនៅក្នុងការជ្រើសរើស និង ការអនុវត្តសេវា និង ការពិនិត្យតាមដានលើសេវានោះ ដើម្បីឱ្យអ្នកផ្តល់មានការទទួលខុសត្រូវ ។ ការងារនេះត្រូវបានសាកល្បងនៅក្នុងគំរោងនៅប្រទេសអែលសាវ៉ាឌ័រ ទុយនេស៊ី និង យូហ្គង់ដា ។ កម្មវិធីកសាងទ្រព្យសម្បត្តិរបស់ជនក្រីក្រ រួមមាន ការពង្រីកយ៉ាងទូលំទូលាយលើការសិក្សានៅសាលារៀន ដោយមានការចូលរួមរបស់ឪពុកម្តាយ និង សហគមន៍ កម្មវិធីស្នាក់នៅក្នុងសាលារៀន (ដូចជា កម្មវិធីនៅប្រទេសបង់ក្លាដេស ប្រេស៊ីល ម៉ិចស៊ិកូ និង ប៉ូឡូញ) កម្មវិធីអាហារូ-

បត្ថម្ភ កម្មវិធីថែទាំសុខភាពមាតា និង ទារក ការចាក់ថ្នាំបង្ការ និង ការធ្វើអន្តរាគមន៍ផ្សេងទៀតផ្នែកសុខាភិបាល និង ផែនការនៅសហគមន៍ដើម្បីការពារធនធានទឹក និង សមាសធាតុផ្សេងទៀតនៃបរិស្ថានធម្មជាតិ។

មានការបំពេញបន្ថែមឱ្យគ្នាយ៉ាងខ្លាំងក្លារវាងសកម្មភាពនៅក្នុងតំបន់ខុសៗគ្នា។ ដោយសារតែទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងទ្រព្យសម្បត្តិមនុស្ស និងទ្រព្យសម្បត្តិរូបី ជាឧទាហរណ៍ ការកែលំអការទទួលបានឱកាសប្រើប្រាស់ថាមពល ឬប្រព័ន្ធគមនាគមន៍របស់ប្រជាជនក្រីក្រ អាចបង្កើនឱកាសនិងការត្រលប់ចូលសិក្សាវិញរបស់ពួកគេ។ ហើយការកែលំអបរិស្ថានអាចមានប្រសិទ្ធិភាពយ៉ាងខ្លាំង ចំពោះការកាត់បន្ថយភាពក្រីក្រ។ បញ្ហានេះត្រូវបានកត់ត្រាទុកយ៉ាងល្អដោយយោងទៅលើការទទួលបាននូវផលចំណេញយ៉ាងច្រើនចំពោះសុខភាពពីការកាត់បន្ថយការ បំពុលបរិយាកាស និងទឹក ដែលជាឥទ្ធិពលដ៏ធំមួយលើជំងឺគ្រោះថ្នាក់ផ្សេងៗដែលកើតលើប្រជាជនក្រីក្រ រាប់បញ្ចូលទាំង ជំងឺរាគរុះចំពោះកុមារ និងការប៉ះពាល់ដល់ប្រព័ន្ធដកដង្ហើម ។

*ការដោះស្រាយវិសមភាពនៃទ្រព្យធនចំពោះការបែងចែកយេនឌ័រ ជនជាតិភាគតិច ជាតិសាសន៍ និងសង្គម។* គេតំរូវអោយមានវិធានការពិសេសនានានៅក្នុងសង្គមជាច្រើន ដើម្បីដោះស្រាយវិសមភាពទ្រព្យសម្បត្តិដែលមាននៅក្នុងសង្គម។ ទោះបីជាការលំបាកផ្នែកនយោបាយ និងសង្គមជា ញឹកញាប់រារាំងដល់ការផ្លាស់ប្តូរក៏ដោយ ក៏នៅមានគំរូនៃយន្តការជាច្រើនទៀតអាចដំណើរការបានដែរ ដោយប្រើប្រាស់ការចំណាយសាធារណៈចំរុះមួយ ការផ្លាស់ប្តូរស្ថាប័ន និងការចូលរួម។ បញ្ហាទីមួយ គឺត្រូវពិភាក្សាអំពីកំណែទំរង់ដីធ្លី ដែលគាំទ្រជាសាធារណៈ ដើម្បីជួយកសិករតូចតាច ជាឧទាហរណ៍ ដូចជា នៅតំបន់ព្សសាននៃប្រទេសប្រេស៊ីល និងប្រទេសហ្វីលីពីន។ បញ្ហាមួយទៀត គឺការនាំក្មេងស្រីឱ្យចូលរៀន ដូចជាការផ្តល់លុយកាក់ ឬម្ហូបអាហារដល់ការរៀនសូត្ររបស់គេ ដូចនៅប្រទេសបង់ក្លាដេស ប្រេស៊ីល និងម៉ិកស៊ិកូ ព្រមទាំងជួលអ្នកគ្រូបន្ថែមទៀត ដូចនៅប្រទេសប៉ាហ្គីស្ថាន។ បញ្ហាទី៣ គឺផ្តល់ការគាំទ្រចំពោះគំរោងឥណទានខ្នាតតូចសំរាប់ស្ត្រីក្រីក្រ។

*ផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងចំណេះដឹងដល់តំបន់ក្រីក្រ ទាំងនៅជនបទ និងទីក្រុង។* គេក៏ត្រូវការនូវវិធានការពិសេសផងដែរនៅក្នុងតំបន់ក្រីក្រ ដែលបន្សំនៃភាពខ្វះខាតទ្រព្យធននានា (រួមទាំងនៅថ្នាក់សហគមនិងថ្នាក់តំបន់) អាចធ្វើអោយក្តីសង្ឃឹមរបស់អ្នកក្រីក្រថយចុះ។ ការដោះស្រាយបញ្ហានេះតំរូវអោយមានការគាំទ្រជាសាធារណៈពីស្ថាប័ន និងត្រូវការរបៀបដោះស្រាយនានាជាលក្ខណៈស្ថាប័ននិងដែលទាមទារឱ្យមានការចូលរួម។ វាក៏ទាមទារឱ្យផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធសង្គមនិងសេដ្ឋកិច្ច នៅតំបន់ក្រីក្រដាច់ស្រយាលនានាដោយរួមបញ្ចូលទាំងផ្លូវគមនាគមន៍ ទូរគមនាគមន៍ សាលារៀន សេវាសុខភាព និងអគ្គិសនី ដូចមាននៅក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ក្រីក្ររបស់ប្រទេសចិន។ វាក៏តម្រូវអោយមានការផ្តល់ផងដែរ នូវសេវាកម្មដែលចាំបាច់ក្នុងទីក្រុង ដែលមានតំបន់មនុស្សក្រីក្ររស់នៅដោយស្របទៅនឹងយុទ្ធសាស្ត្រទូទៅមួយរបស់ទីក្រុង។ ការបង្កើនឱកាសក្នុងការប្រើប្រាស់ពិតមានសំរាប់ភូមិ

ក្រីក្រនានា ក៏មានសារៈសំខាន់ផងដែរ ដើម្បីអោយពួកគាត់ចូលរួមក្នុងទីផ្សារ និងត្រួតពិនិត្យរដ្ឋាភិបាលមូលដ្ឋាន។

*__ការផ្តល់អំណាចៈ__*

សក្តានុពលសំរាប់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ត្រូវបានទទួលងតទ្ធិពលយ៉ាងខ្លាំងពីស្ថាប័នរដ្ឋ និងសង្គម។ សកម្មភាពកែលំអមុខងាររបស់ស្ថាប័នរដ្ឋ និងសង្គម គឺកែលំអទាំងកំណើន និងសមធម៌ តាមរយៈការកាត់បន្ថយបញ្ហាលំបាកនៃការិយាល័យធិបតេយ្យនិងសង្គម ដែលប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ច និងចល័តភាពដែលមានកំរិតខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ ការបង្កើត និងការអនុវត្តការផ្លាស់ប្តូរទាំងនេះ គឺទាមទារអោយមានឆន្ទៈនយោបាយខ្ពស់ ជាពិសេសនៅពេលដែលការផ្លាស់ប្តូរទាំងនេះប្រឈមមុខយ៉ាង ខ្លាំងចំពោះតំលៃសង្គម ឬផលប្រយោជន៍ចាក់គ្រឹះ។ រដ្ឋាភិបាលអាចធ្វើបានច្រើនក្នុងការបញ្ចូលការពិភាក្សាជាសាធារណៈ ដើម្បីបង្កើនការយល់ដឹងអំពីផលប្រយោជន៍សង្គមលើសកម្មភាពសាធារណៈដែលគាំទ្រអ្នកក្រីក្រ និងបង្កើតការគាំទ្រផ្នែកនយោបាយលើសកម្មភាពទាំងនេះ។

*ដាក់មូលដ្ឋាននយោបាយ និងច្បាប់សំរាប់ការអភិវឌ្ឍន៍រួម។* ស្ថាប័នរដ្ឋនានាត្រូវការបើកទូទាយ និងទទួលខុសត្រូវចំពោះកិច្ចការទាំងអស់។ នេះមានន័យថា គឺមានស្ថាប័នតម្លាភាព ដោយមានយន្តការប្រជាធិបតេយ្យ និងការចូលរួម សំរាប់ការធ្វើការសំរេចនានា និងការតាមដានការអនុវត្តន៏របស់ពួកគេគាំទ្រដោយប្រព័ន្ធច្បាប់ ដែលជំរុញកំណើនសេដ្ឋកិច្ច និងលើកកំពស់សមធម៌នៃច្បាប់។ ចាប់តាំងពីអ្នកក្រខ្វះធនធាន និងពត៌មាន ដើម្បីទទួលបានប្រព័ន្ធច្បាប់វិធានការនានា ដូចជាជំនួយផ្នែកច្បាប់ និងការផ្សព្វផ្សាយពត៌មានស្តីអំពីនិតិវិធីច្បាប់ ជាឧទាហរណ៍អង្គការ Ain-OSalish Kendra (ASK) នៅក្នុងប្រទេសបង់ក្លាដេសដ៏ គឺជាមធ្យោបាយដ៏មានអំណាចសំរាប់បង្កើតប្រព័ន្ធច្បាប់រួម និងដែលមានការទទួលខុសត្រូវ។

*បង្កើតរដ្ឋបាលសាធារណៈដែលជំរុញកំណើននិងសមធម៌។* រដ្ឋបាលសាធារណៈដែលអនុវត្តប្រសិទ្ធិភាពគោលនយោបាយ និងពុំមានអំពើពុករលួយ ឬរុកគួន គឺបានធ្វើអោយប្រសើរនូវការផ្តល់សេវាផ្តល់អោយដោយវិស័យសាធារណៈ និងសំរាប់សំរបសំរួលកំណើនវិស័យឯកជន។ ការលើកទឹកចិត្តនៃការអនុវត្តដ៏សមរម្យ គឺត្រូវការដើម្បីធ្វើអោយរដ្ឋបាលសាធារណៈមានភាពទទួលខុសត្រូវ និងឆ្លើយតបចំពោះអ្នកប្រើប្រាស់។ ការទទួលពត៌មាន ដូចជា ថវិកាចំណាយយន្តការថវិកាចំណាយដែលមានការចូលរួម និងការអនុវត្តន៏នៃសេវាសាធារណៈ គឺធ្វើអោយប្រសើរលទ្ធភាពរបស់ប្រជាពលរដ្ឋ ដើម្បីជួយនិងពិនិត្យមើលការប្រតិបត្តិវិស័យសាធារណៈ ដែលអាចកាត់បន្ថយឱកាសសំរាប់ប្រព្រឹត្តអំពើពុករលួយ។ ការកែទំរង់រដ្ឋបាលសាធារណៈ និងភ្នាក់ងារឯទៀតៗដូចជាប៉ូលីសដើម្បីបង្កើតការទទួលខុសត្រូវ និងការឆ្លើយតបរបស់គេចំពោះអ្នកក្រ ព្រោះវាអាចជួយអោយជីវិតរបស់ពួកគេប្រសើរឡើង។

*លើកកំពស់វិមជ្ឈការនិងការអភិវឌ្ឍសហគមន៍។*

វិមជ្ឈការអាចនាំយកភ្នាក់ងារសេវាកម្មអោយចូលកាន់តែជិតសហគមន៍ក្រីក្រ និងអ្នកក្រ ដោយលើកកំពស់ការត្រួតពិនិត្យមើលសេវាកម្មរបស់ប្រជាជន ដែលពួកគេមានសិទ្ធិទទួលបាន។ ទាំងនេះ តំរូវអោយមានការពង្រឹងសមត្ថភាពមូលដ្ឋាននិងការប្រគល់ធនធានហិរញ្ញវត្ថុ។ វាក៏តំរូវចាំបាច់អោយមានវិធានការ ដើម្បីជៀសវាងការរឹបអូសយកទ្រព្យសម្បត្តិពីជនមានអំណាចនៅក្នុងមូលដ្ឋាន។ វិមជ្ឈការត្រូវការរួមបញ្ចូលទាំងយន្តការប្រសិទ្ធិភាពសំរាប់ការចូលរួមយ៉ាងសកម្ម និងការតាមដានរបស់ប្រជាពលរដ្ឋលើភ្នាក់ងាររបស់រដ្ឋា-ភិបាល។ គំរូជាច្រើនរួមមានវិមជ្ឈការ ដែលជំរុញការជ្រើសរើសរបស់សហគមក្នុងការប្រើប្រាស់ធនធាន និងការអនុវត្តគំរោង។ វាក៏មានជំរើសជាច្រើនដែរសំរាប់សហគមន៍ និងក្រុមគ្រួសារដែលកំពុងជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពលើវិស័យនានា ដូចជាការចូលរួមរបស់អាណាព្យាបាលសិស្សនៅតាមសាលា និងសមាគមន៍អ្នកប្រើប្រាស់ទឹក និងប្រព័ន្ធស្រោចស្រព។

*លើកកំពស់សមធមិយែនឌ័រ។*

ទំនាក់ទំនងនៃយេនឌ័រដែលមានលក្ខណមិនស្មើភាពគ្នាគឺជាបញ្ហាដ៏ធំធេងមួយចំពោះវិសមភាពសង្គម ដោយអាស្រ័យលើតំលៃនិងបទដ្ឋានសង្គម។ ប៉ុន្តែ សមភាពយែនឌ័រ គឺមានសារៈសំខាន់ខ្លាំងណាស់ ដែលវាគួរនឹងទទួលបាននូវការសង្កត់ធ្ងន់បន្ថែមទៀត។ នៅខណៈដែលគំរូនៃវិសមភាពយែនឌ័រមានការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងសង្គមជាច្រើន ភាគច្រើននៃស្ត្រីនិងក្មេងស្រីនៅស្ទើរតែគ្រប់ប្រទេសទាំងអស់បានបាត់បង់ឱកាសក្នុងអំណាចនានា និងការគ្រប់គ្រងធនធាន (នៅក្នុងប្រទេសភាគច្រើន ប្លង់កម្មសិទ្ធិដីនៅក្នុងកណ្តាប់ដៃមនុស្សប្រុស) ហើយពួកគេជួបប្រទះនូវអសន្តិសុខធ្ងន់ធ្ងរ (ឧទាហរណ៍ បន្ទាប់ពីប្តីរបស់ខ្លួនបានស្លាប់)។ ដូច្នេះ ស្ត្រីក្រីក្របានបាត់បង់ឱកាសនេះទ្វេរដង។ លើសពីនេះ ការខ្វះខាតនូវឯករាជ្យភាពរបស់ស្ត្រី វាមានផលប៉ះពាល់ជាអវិជ្ជមានចំពោះការអប់រំ ក៏ដូចជាថែទាំសុខភាពក្មេងៗដែរ។

សមធមិយែនឌ័រ មានសារប្រយោជន៏ចំពោះសិទ្ធិផ្ទាល់ខ្លួន និងមានសារប្រយោជន៏ចំពោះសេដ្ឋកិច្ចនិងសង្គមក្នុងការកាត់បន្ថយភាពក្រីក្រ។ ឧទាហរណ៏មានការរីកចំរើនខ្លះនៅក្នុងវិស័យអប់រំនិងសុខាភិបាល ក៏ប៉ុន្តែ នៅមានវិស័យជាច្រើនទៀតដែលចាំបាច់ត្រូវតែសំរេចអោយបាន។ បទពិសោធន៏បានបង្ហាញថា គឺត្រូវអោយមានការរួបរួមគ្នាទាំងនយោបាយ ច្បាប់ និងសកម្មភាពសាធារណៈដោយផ្ទាល់។ ប្រទេស ៣២ ដោយរាប់ចាប់ពីប្រទេសអាសង់ទីនមកដល់ឥណ្ឌា មានវិធានការជាច្រើន ដើម្បីលើកកំពស់តំណាងរបស់ស្ត្រីនៅក្នុងជុំនុំមូលដ្ឋាននិងថ្នាក់ជាតិ ហើយវិធានការនេះកំពុងតែបានឱ្យស្ត្រីមានលទ្ធភាពចូលរួមក្នុងជីវិតសាធារណៈ និងការសំរេចចិត្តនានា។ ប្រទេសខ្លះកំពុងកែតំរូវភាពលំអៀងនៃយែនឌ័រនៅក្នុងច្បាប់ ដូចជាមានការកែតំរូវនៅក្នុងច្បាប់ដែលទាក់ទងនឹងដីធ្លីឆ្នាំ ១៩៩៤ របស់ប្រទេសកូឡុំប៊ី។ ការប្រើប្រាស់ធនធានសាធា-រណៈសំរាប់ជួយទំនុកបំរុងដល់ការសិក្សារបស់ក្មេងស្រីត្រូវបានគេបង្ហាញអោយឃើញថា បានទទួលជោគជ័យនៅប្រទេសបង់ក្លាដេសដ៏ និងប៉ាហ្គីស្ថាន។ វិធានការជាច្រើននៅក្នុងសកម្មភាពផលិតកម្ម ជាពិសេស

នៅក្នុងមីក្រូហិរញ្ញវត្ថុ និងធាតុចូលរបស់កសិកម្ម បានផ្ដល់នូវអត្ថប្រយោជន៍ជាច្រើនដែលមានបង្ហាញក្នុងឯកសារ ដោយយោងតាមទិន្នផលដែលបានកើនឡើង (ជាឧទាហរណ៍នៅប្រទេសកេនយ៉ា) និងដោយយោងតាមឯករាជ្យភាពរបស់ស្ត្រីដែលបានកើនឡើង និងដោយយោងតាមស្ថានភាពដែលកាន់តែប្រសើរឡើងនៃអាហារូបត្ថម្ភសំរាប់កូនក្មេង (នៅក្នុងប្រទេសបង់ក្លាដេសដ៏ និងនៅស្ទើរតែគ្រប់ប្រទេស ដែលបញ្ហានេះត្រូវបានគេត្រួតពិនត្យ)។

*ដោះស្រាយឧបសគ្គសង្គម។* ស្ថាប័ន និងរចនាសម្ព័ន្ធសង្គម បង្កើតជាក្របខ័ណ្ឌសំរាប់ទំនាក់ទំនងសេដ្ឋកិច្ចនិងនយោបាយ និងធ្វើអោយមានកំលាំងឱណាម៉ិចជាច្រើនដែលបង្កើត និងគាំទ្រការកាត់បន្ថយភាពក្រីក្រ។ រចនាសម្ព័នសង្គម ដែលមិនត្រូវបានគេរាប់បញ្ចូល និងវិសមភាព ដូចជាចំណាត់ថ្នាក់វណ្ណៈ ឬការបែងចែកយេនឌ័រ គឺជាឧបសគ្គចំបងចំពោះចល័តភាពដែលកំពុងកើនឡើងរបស់ប្រជាជនក្រីក្រ។ រដ្ឋាភិបាលអាចជួយដោយជំរុញការពិភាក្សាលើការប្រតិបត្តិដែលមិនត្រូវបានគេរាប់បញ្ចូល ឬផ្នែកនានាដែលមានភាពមិនប្រក្រតី និងដោយគាំទ្រចំពោះការសន្យា និងការចូលរួមពីតំណាងក្រុម ដែលគេមិនរាប់បញ្ចូលទៅក្នុងសង្គម។ ក្រុមដែលប្រឈមមុខទៅនឹងការរើសអើងសកម្ម អាចជួយបានតាមរយៈគោលនយោបាយទប់ស្កាត់ការរើសអើងឬប្រកាន់ជាតិសាសន៍ក្នុងការងារ។ ភាពបែកបាក់សង្គមអាចកាត់បន្ថយបានដោយការនាំក្រុមទាំងអស់ឱ្យមកជួបជុំគ្នានៅក្នុងវេទិកាផ្លូវការនិងក្រៅផ្លូវការ ហើយនិងបញ្ជូនថាមពលរបស់ពួកគេទៅក្នុងដំណើរការនយោបាយជាជាងបង្កើតអោយមានជំលោះ។ សកម្មភាពផ្សេងៗទៀតរួមមានការលប់បំបាត់ចោលភាពលំអៀងលើជាតិភាគតិចជាតិសាសន៍ និងយេនឌ័រនៅក្នុងអង្គនីតិបញ្ញត្តិ និងការប្រតិបត្តិប្រព័ន្ធច្បាប់ និងការលើកទឹកចិត្តចំពោះតំណាង និងសំលេងរបស់ស្ត្រី និងក្រុមជនជាតិភាគតិច និងជាតិសាសន៍ដែលគ្មានឱកាសនៅក្នុងសហគមន៍ និងអង្គការជាតិ ។

*ការគាំទ្រធនធានសង្គមរបស់ប្រជាជនក្រីក្រ។*
បទដ្ឋាន និងបណ្ដាញសង្គម គឺជាប្រភេទនៃធនធានដ៏សំខាន់មួយ ដែលប្រជាជនអាចប្រើប្រាស់ ដើម្បីចេញអោយផុតពីភាពក្រីក្រ។ ដូច្នេះ ធនធាននេះមានសារសំខាន់ណាស់ក្នុងការរួមចំណែក និងគាំទ្របណ្ដាញនៃប្រជាជនក្រីក្រ និងលើកកំពស់សក្ដានុពលភាពរបស់ពួកគេ ដោយផ្សាភ្ជាប់ពួកគេទៅនឹងអង្គការអន្តរការីនានា ទីផ្សារទូលំទូលាយ និងស្ថាប័នសាធារណៈ។ ការធ្វើដូច្នេះក៏ទាមទារផងដែរនូវការកែលំអបរិស្ថានច្បាប់ និយតកម្ម និងស្ថាប័នសំរាប់ក្រុមដែលជាតំណាងអោយប្រជាជនក្រីក្រ។ នៅពេលដែលប្រជាជនក្រីក្របានរៀបចំនៅថ្នាក់មូលដ្ឋាន សកម្មភាពនេះក៏នឹងត្រូវការចាំបាច់ដើម្បីពង្រឹងសមត្ថភាពពួកគេ ដើម្បីអោយមានឥទ្ធិពលទៅលើគោលនយោបាយថ្នាក់រដ្ឋ និងថ្នាក់ជាតិ ដូចជា ការផ្សាភ្ជាប់អង្គការមូលដ្ឋានទៅនឹងអង្គការធំៗនានា ។

***<u>សន្តិសុខ:</u>***

ការទទួលបានសន្តិសុខពេញលេញ ទាមទារអោយមានការផ្ដោតការយកចិត្តទុកដាក់អោយកាន់តែខ្ពស់

ថែមទៀត ទៅលើថាតើអសន្តិសុខប៉ះពាល់ការរស់នៅ និងសេចក្ដីសង្ឃឹមរបស់ប្រជាជនក្រីក្រយ៉ាងណា។ គេក៏ត្រូវការប្រើប្រាស់វិធានការចំរុះមួយ ដើម្បីដោះស្រាយហានិភ័យសេដ្ឋកិច្ចទូទៅ ឬទូទាំងតំបន់ និងដើម្បីជួយប្រជាជនក្រីក្រលែលកដោះស្រាយផលប៉ះពាល់អវិជ្ជមាននានា។

*រៀបចំឱ្យបានជាក់លាក់នូវរបៀបដោះស្រាយមួយដែលមានរចនាបទត្រឹមត្រូវដើម្បីជួយប្រជាជនក្រីក្រគប់គ្រងហានិភ័យនានា។* ការអន្តរាគមន៍ខុសៗគ្នា នៅឯថ្នាក់សហគមន៍ ទីផ្សារ និងថ្នាក់រដ្ឋ គឺត្រូវការចាំបាច់ដើម្បីដោះស្រាយហានិភ័យផ្សេងៗគ្នា និងការទាស់ទែងគ្នាផ្សេងៗរបស់ប្រជាជន។ អន្តរាគមន៍ចំរុះមួយប្រហែលជាត្រូវការដើម្បីគាំទ្រដល់ការគ្រប់គ្រងហានីភ័យសំរាប់សហគមន៍ និងក្រុមគ្រួសារនានា ដោយអាស្រ័យទៅនឹងប្រភេទនៃហានីភ័យ និងសមត្ថភាពស្ថាប័នរបស់ប្រទេសនោះ។ កម្មវិធីធានារ៉ាប់រងខ្នាតតូច អាចជួយបំពេញដល់កម្មវិធីមីក្រូឥណទានសំរាប់ស្ត្រីក្រីក្រ បង្កើតអង្គការសំរាប់ស្ត្រី ដូចជាគំរោងមួយឈ្មោះថា SEWA ដែលដំណើរការនៅប្រទេសឥណ្ឌាសំរាប់ស្ត្រីក្នុងវិស័យមិនផ្លូវការ។ គំរោងសាធារណការ អាចពង្រីកបានក្នុងការឆ្លើយតបចំពោះផលប៉ះពាល់ដែលកើតមាននៅថ្នាក់មូលដ្ឋាន ឬថ្នាក់ជាតិ។ កម្មវិធីផ្ទេរស្បៀងអាហារ និងមូលនិធិសង្គមសំរាប់ជួយផ្ដល់ហិរញ្ញប្បទានដល់គំរោងនានា ដែលមានការចូលរួមពាក់ព័ន្ធយ៉ាងជិតស្និទ្ធពីសហគមន៍ទាំងឡាយ ក៏អាចមានប្រសិទ្ធភាពក្នុងការដោះស្រាយគ្រោះមហន្តរាយនានាផងដែរ។

*អភិវឌ្ឍកម្មវិធីជាតិដើម្បីទប់ស្កាត់ រៀបចំ និងឆ្លើយតបទៅនឹងផលប៉ះពាល់ធំៗ ដូចជា ផលប៉ះពាល់លើហិរញ្ញវត្ថុ និងធម្មជាតិ។* ផលប៉ះពាល់សេដ្ឋកិច្ចគឺជាបញ្ហាដែលលំបាកបំផុតសំរាប់សហគមន៍ និងក្រុមគ្រួសារក្រីក្រ ក្នុងការដោះស្រាយ ជាពិសេសនៅពេលដែលផលប៉ះពាល់ទាំងនោះកើតឡើងម្ដងហើយម្ដងទៀត មានភាពធ្ងន់ធ្ងរ ឬរ៉ាំរ៉ៃ។ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដែលមានស្ថេរភាព និងប្រពន្ធ័ហិរញ្ញវត្ថុរឹងមាំ គឺជាមូលដ្ឋានគ្រឹះ សំរាប់គ្រប់គ្រងហានិភ័យនៃផលប៉ះពាល់ដល់ហិរញ្ញាវត្ថុ និងផលប៉ះពាល់ដល់ពាណិជ្ជកម្ម។ ប៉ុន្តែ គោលនយោបាយនិងប្រព័ន្ធទាំងនេះត្រូវតែបានបំពេញបន្ថែមដោយការគ្រប់គ្រងដែលមានលក្ខណប្រុងប្រយត្ន័ ក្នុងការបើកគណនីទុន ដើម្បីកាត់បន្ថយហានីភ័យនៃលំហូររយៈពេលខ្លីដែលមិនស្ថិតស្ថេរ។ វិធានការពិសេសៗជាច្រើន គឺត្រូវការចាំបាច់ផងដែរ ដើម្បីធានាថាការចំណាយទៅលើកម្មវិធីនានាដែលមានសារសំខាន់ចំពោះប្រជាជនក្រីក្រ (ដូចជា កម្មវីធីសង្គម និងកម្មវិធីផ្ទេរស្បៀងអាហារគោលដៅ) មិនមានការធ្លាក់ចុះទេ ក្នុងកំឡុងពេលដែលសេដ្ឋកិច្ចធ្លាក់ចុះ ជាពិសេសទាក់ ទងនៅនឹងតំរូវការកើនឡើង។ សារៈសំខាន់ដូចគ្នានេះដែរ បណ្ដាញការពារប្រឆាំងនឹងបញ្ហាដែលកើតឡើងដដែលៗ គួរតែមានជាអចិន្ត្រៃយ៍ និងត្រៀមរួចស្រេចសំរាប់ដាក់ពង្រាយ នៅពេលដែលប្រទេសទាំងឡាយណាទទួលរងនូវផលប៉ះពាល់។ សកម្មភាពទាំងនេះ និងសកម្មភាពផ្សេងៗទៀត ក៏អាចជួយក្នុងការដោះស្រាយផលប៉ះពាល់ធម្មជាតិដែរ។ "មូលនិធិ Calamity" អាចផ្ដល់ហិរញ្ញប្បទានដល់គំរោងសង្គ្រោះបន្ទាន់ បន្ទាប់ពី

មានគ្រោះមហន្តរាយធម្មជាតិនានា និងគាំទ្រការបណ្តុះបណ្តាលនិងបច្ចេកវិទ្យាថ្មីសំរាប់វាយតំលៃអោយបានប្រសើរចំពោះហានិភ័យនោះ។ ការរៀបចំអោយមានវិនិយោគទុន និងការធានារ៉ាប់រងនៅក្នុងពេលវេលាធម្មតា អាចកាត់បន្ថយតំលៃចំណាយផ្ទាល់ខ្លួននៅពេលដែលមានគ្រោះមហន្តរាយកើតឡើង។

*បង្កើតប្រពន្ធ័ជាតិសំរាប់គ្រប់គ្រងហានីភ័យសង្គម វាក៏ជួយអោយមានកំណើនដែរ។* មានតំរូវការនៅទូទាំងពិភពលោក សំរាប់ប្រពន្ធ័ជាតិគ្រប់គ្រងហានីភ័យសង្គម។ បញ្ហាប្រឈមចំពោះមុខ គឺត្រូវបង្កើតប្រព័ន្ធជាតិនេះឡើង ដើម្បីកុំអោយគេកាត់បន្ថយភាពប្រកួតប្រជែង និងដើម្បីអោយប្រជាជនក្រីក្រទទួលបានផលប្រយោជន៍។ សូមលើកយកឧទាហរណ៍ខ្លះៗមកបង្ហាញៈ ប្រពន្ធ័នានាដែលផ្តល់ទាំងការធានារ៉ាប់រងសំរាប់ប្រជាជនមិនមែនក្រីក្រ និងរួមបញ្ចូលទាំងប្រព័ន្ធសោធន៏សង្គមសំរាប់អ្នកក្រ ដូចនៅប្រទេសឈីលី។ ការធានារ៉ាប់រងចំពោះសុខភាព ដែលការពារប្រឆាំងនឹងជំងឺដែលបង្កគ្រោះមហន្តរាយ ដែលអាចធ្វើឱ្យបាត់បង់ទ្រព្យធនក្នុងគ្រួសារ ដូចជានៅប្រទេសកូស្តារិកា។ ការធានារ៉ាប់រងចំពោះការអត់ការងារធ្វើ និងជំនួយនានា ដែលមិនបានសំរបសំរួលផ្តល់ការលើកទឹកចិត្តក្នុងការបំពេញការងារ។ ក៏ប៉ុន្តែ ដើម្បីទទួលបានផលប្រយោជន៏ពេញលេញពីគំរោងនេះ សេដ្ឋកិច្ចត្រូវការចាំបាច់នូវសមត្ថភាពស្ថាប័ន ដើម្បីគ្រប់គ្រងគំរោងទាំងនេះអោយមានប្រសិទ្ធភាព។

*ដោះស្រាយជំលោះស៊ីវិល។* ជំលោះស៊ីវិលកំពុងតែបង្កគ្រោះមហន្តរាយដល់អ្នកក្រៈ ទំហំនៃជំលោះជាច្រើនកើតឡើងក្នុងប្រទេសក្រីក្រ ហើយភាគច្រើនគឺជាសង្គ្រាមស៊ីវិល ដែលគេសង្កេតឃើញថាច្រើនជាង ៨៥ភាគរយនៃជំលោះទាំងនោះបានកើតមានឡើងនៅតាមព្រំដែននៃប្រទេស ក្នុងចន្លោះពីឆ្នាំ ១៩៨៧ ដល់ ១៩៩៧។ បន្ថែមពីលើការបាត់បង់ជីវិតមនុស្សដោយផ្ទាល់ សង្គ្រាមបានធ្វើអោយសង្គម និងសេដ្ឋកិច្ចទទួលរងការបំផ្លិចបំផ្លាញ និងបង្កើតអោយមានផលអាក្រក់ដែលប៉ះទង្គិចយ៉ាងខ្លាំងដល់ចិត្តសាស្ត្រ និងសង្គម។ ក្មេងៗត្រូវបានគេបង្ខំអោយធ្វើជាទាហានកាន់កាំភ្លើងប្រយុទ្ធគ្នា ដូចជា នៅប្រទេសសេរាលេអូន និងមានក្មេងៗជាច្រើនទៀត ទទួលរងការព្រាត់ប្រាស់និរាស្តគ្រួសារ បន្ទុចបង្អាក់ការសិក្សា និងមានអារម្មណ៏ភ័យខ្លាចដក់ជាប់ក្នុងខ្លួន ដែលបញ្ហានេះបានកាត់បន្ថយក្តីសង្ឃឹមរបស់គេទៅអនាគត។

វាមានសារៈសំខាន់ណាស់ សំរាប់ការផ្តោតទៅលើការកសាងសង្គមក្រោយសង្គ្រាម ដូចជានៅប្រទេសកម្ពុជា និងប្រទេសរ៉ូវ៉ាន់ដា ហើយតំរូវឱ្យមានវិធានជាបន្ទាន់ដើម្បីទប់ស្កាត់ជំលោះនេះ។ មានភស្តុតាងជាច្រើនថា ការពង្រឹងស្ថាប័នចំរុះ (ដូចជាការគាំទ្រសិទ្ធិសេរីភាព និងផ្តល់មូលដ្ឋានគ្រឹះសំរាប់ស្ថាប័នសំរាប់ដំណោះស្រាយជំលោះដោយសន្តិវិធី) គឺមានឥទ្ធិពលខ្លាំងណាស់។ កិច្ចប្រឹងប្រែងនានាដើម្បីទប់ស្កាត់ជំលោះក៏មានសារៈសំខាន់ផងដែរ ដើម្បីធ្វើអោយក្រុមផ្សេងៗគ្នាមានអន្តរកម្មលើគ្នាទៅវិញទៅមកតាមរយៈស្ថាប័ននយោបាយដែលចូលរួម និងតាមរយៈស្ថាប័នស៊ីវិល។ ដូចដែលបានកត់ត្រាខាងក្រោមនេះ សក-ម្មភាពជាអន្តរជាតិដើម្បីកាត់បន្ថយការចំណាយលុយក្នុងជំលោះ និងកាត់បន្ថយការជួញដូរសព្វាវុធជាអន្តរជាតិ ក៏មានសារៈសំខាន់ណាស់ដែរ។ ប្រសិនបើ

ប្រទេសនានាអាចដើរលើគន្លងមួយនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចដែលមានលក្ខណទូលំទូលាយ នោះពួកគេមានសក្តានុពលភាពដើម្បីផ្លាស់ប្តូរពីមជ្ឈដ្ឋានកាចសាហាវមួយទៅមជ្ឈដ្ឋានដែលប្រកបដោយគុណធម៌វិញ។ ជំលោះហឹង្សាជាផ្នែកមួយ ដែលត្រូវដោះស្រាយជាបន្ទាន់សំរាប់កាត់បន្ថយការប៉ះពាល់ដល់ប្រជាជនក្រីក្រជាងគេ ដែលរស់នៅលើពិភពលោក ។

*ដោះស្រាយការឆ្លងរាលដាលជំងឺអ៊ីវ/អេដស៍ ។* ជំងឺអ៊ីវ/អេដស៍គឺជាប្រភពនៃអសន្តិសុខមួយដែលសំខាន់ជាងគេបំផុតក្នុងចំណោមប្រភពអសន្តិសុខជាច្រើននៅក្នុងប្រទេសដែលទទួលរងគ្រោះនានាក្នុងទ្វីបអាហ្វ្រិក។ នៅពេលដែលឥទ្ធិពលនៃការបំផ្លាញកើតមានលើបុគ្គលនិងគ្រួសារ ផលវិបាកផ្សេងៗក៏កាន់តែកើនឡើង គឺកើតចេញពីការលំបាកដែលមិនអាចទ្រាំទ្របានលើយន្តការផ្គត់ផ្គង់កុមារតាមបែបបុរាណទៅជាការគាបសង្កត់ធ្ងន់ធ្ងរលើប្រព័ន្ធសុខភាព និងបាត់បង់កំលាំងផលិតកម្មដែលជះឥទ្ធិពលដល់សហគមន៍ និងសង្គមជាតិទាំងមូល។ ប្រជាជនច្រើនជាង ៣៤លាននាក់ នៅលើពិភពលោកនេះ ទទួលរងជំងឺអ៊ីវ (៩០ភាគរយ នៅក្នុងប្រទេសកំពុងអភិឌ្ឍ) ហើយច្រើនជាង ៥លាននាក់ ប៉ះពាល់ដោយជំងឺនេះរៀងរាល់ឆ្នាំ។ មនុស្សច្រើនជាង ១៨លាន់នាក់ បានស្លាប់ដោយជំងឺអេដស៍នេះ។ សកម្មភាពនៅថ្នាក់អន្តរជាតិ ដើម្បីបង្កើតវ៉ាក់សាំងសំរាប់ការពារជំងឺអេដស៍ គឺជាកិច្ចការសំខាន់សំរាប់អនាគត ប៉ុន្តែតាមរយៈបទពិសោធន៍ខុសៗគ្នា បានបង្ហាញឱ្យឃើញថា អ្វីដែលនឹងធ្វើឱ្យមានភាពខុសគ្នាមួយនាពេលនេះ គឺមានការយល់ជ្រួតជ្រាបនៃភាពជាអ្នកដឹកនាំ និងការផ្លាស់ប្តូរសង្គមមួយដើម្បីទប់ស្កាត់ការរាលដាលនៃជំងឺអ៊ីវ និងការមើលថែរក្សាអ្នកដែលបានកើតជំងឺនេះ។ កិច្ចការនេះរួមបញ្ចូលទាំងការប្រយុទ្ធតទល់នឹងការហាមប្រាមការរកស៊ីផ្លូវភេទ ផ្តល់ពតិមានដល់ជនដែលជាគោលដៅ និងគាំទ្រដល់ក្រុមដែលងាយរងគ្រោះខ្លាំង ដូចជាស្ត្រីរកស៊ីផ្លូវភេទ និងផ្តល់ក្តីមេត្តាដល់អ្នករងគ្រោះដោយជំងឺអេដស៍។ ប្រទេសប្រេស៊ីល សេនេហ្កាល ថៃ និងអ៊ុយហ្គង់ដា បានបង្ហាញអោយឃើញពីអ្វីដែលអាចធ្វើទៅបាននៅពេលដែលមានឆន្ទះដាច់ខាតក្នុងការធ្វើកិច្ចការនោះ។

***សកម្មភាពអន្តរជាតិ :***

សកម្មភាពនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានវានឹងមិនគ្រប់គ្រាន់ទេសំរាប់កាត់បន្ថយភាពក្រីក្រអោយបានឆាប់រហ័សនោះ។ នៅមានវិស័យ(តំបន់)ជាច្រើនដែលទាមទារអោយមានសកម្មភាពជាលក្ខណៈអន្តរជាតិ (ជាពិសេសប្រទេសឧស្សាហកម្ម) ដើម្បីធានាអោយមានផលចំណេញដល់ប្រទេសអ្នកក្រ និងប្រជាជនក្រីក្រនៅប្រទេសកំពុងអភិវឌ្ឍ។ ការផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនឡើងលើការអនុគ្រោះបំណុល និងការសំរបសំរួលឈានទៅរកការសហការអភិឌ្ឍន៍តាមរយៈការប្រើប្រាស់ជំនួយអោយមានប្រសិទ្ធិភាព គឺជាផ្នែកមួយនៃកិច្ចការនេះ។ សកម្មភាពនានានៅក្នុងវិស័យផ្សេងៗទៀត ក៏មានសារៈសំខាន់ដូចៗគ្នាដែរ (ដូចជា ពាណិជ្ជកម្ម វ៉ាក់សាំងសំរាប់ពារការ ការខិតចូលជិតការបែងចែកចំណេះដឹង និងបច្ចេកទេសទំនើប) ដែលអាចលើកកំពស់ឱកាសការផ្តល់អំណាច និងសន្តិសុខ ចំពោះអ្នកក្រ ។

*កាលានុវត្តភាព។* ជាមួយនឹងប្រព័ន្ធពាណិជ្ជកម្ម អាស្រ័យលើច្បាប់ ប្រទេសឧស្សាហកម្មនានាអាច ពង្រីកឱកាសការងារ ដោយការបើកចំហរទីផ្សាររបស់ គេអោយកាន់ធំ ដើម្បីនាំចូលទំនិញនានាពីប្រទេស អ្នកក្រ ជាពិសេស លើវិស័យកសិកម្ម ឧស្សាហកម្មអតិពលកម្មនិងសេវាកម្មនានា។

គេបានប៉ាន់ប្រមាណថាតារាងពន្ធនៃ OECD និងឧបត្ថមធននានា បានបង្កការបាត់បង់ជារៀងរាល់ឆ្នាំចំពោះសុខមាលភាពដែលមានតំលៃប្រមាណ ២០ ពាន់លានដុល្លា នៅប្រទេសកំពុងអភិវឌ្ឍ ដែលស្មើនឹង ៤០ភាគរយៈនៃជំនួយនៅក្នុងឆ្នាំ១៩៩៨។ ប្រទេសកំពុងអភិវឌ្ឍជាច្រើនមានអារម្មណ៍ថា នៅពេលដែលពួកគេកំពុងធ្វើសេរីភាវូបនីយកម្មលើប្រព័ន្ធនយោបាយពាណិជ្ជកម្មរបស់ពួកគេ ទិដ្ឋភាពសំខាន់ៗនៃប្រព័ន្ធនយោបាយពាណិជ្ជកម្មរបស់ប្រទេសអ្នកមាន គឺកំពុងតែទុកឱ្យពួកគាត់បាត់បង់ឱកាសទៅវិញ។ លើសពីនេះទៅទៀត ប្រទេសម្ចាស់ជំនួយអាចជួយពង្រឹងសមត្ថភាពរបស់ប្រទេសកំពុងអភិវឌ្ឍ ដើម្បីបន្តកាត់បន្ថយភាពក្រីក្រ ដោយបង្កើនលំហូរជំនួយទៅកាន់ទៅប្រទេសនានា
ដែលមានបរិយាកាសគោលនយោបាយត្រឹមត្រូវគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ និងតាមរយៈការផ្តល់ហិរញ្ញប្បទានដល់គំនិតផ្តួចផ្តើមអនុគ្រោះបំណុលសំរាប់ប្រទេសក្រីក្រដែលជំពាក់បំណុលច្រើន ដោយផ្តល់ជំនួយបន្ថែមជាជាថវិកា។

*ការផ្តល់អំណាច។* សកម្មភាពសកលអាចផ្តល់អំណាចដល់អ្នកក្រ និងប្រទេសក្រីក្រនៅលើវេទិការជាតិ និងអន្តរជាតិ។ ជំនួយគួរត្រូវបានផ្តល់តាមមធ្យោបាយនានា ដែលធានាអោយទៅដល់ដៃប្រទេសអ្នកទទួល ហើយគេគួរតែបង្កើនកម្មវិធីកាត់បន្ថយភាពក្រីក្រ ដោយបង្កើនការចូលរួមដែលមានប្រសិទ្ធិភាពពីសង្គមស៊ីវិល និងភ្នាក់ងារវិស័យឯកជន។ ប្រជាជនក្រីក្រនិងប្រទេសក្រីក្រ គួរមានសំលេងច្រើនជាងនៅលើវេទិកាអន្តរជាតិ ដើម្បីធានាថា អាទិភាពកិច្ចព្រមព្រាង និងក៏រិតស្តង់ដារ ជាអន្តរជាតិ (ដូចជានៅក្នុងពាណិជ្ជកម្ម និងកម្មសិទ្ធិបញ្ញា) ឆ្លុះបញ្ចាំងអោយឃើញពីតំរូវការ និងផលប្រយោជន៍របស់ពួកគេ។

ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងអង្គការអន្តរជាតិនានា គួរតែបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធានានូវតម្លាភាពពេញលេញនៅក្នុងយុទ្ធសាស្ត្រ និងសកម្មភាពរបស់ខ្លួន និងបើកចំហរការពិគ្រោះយោបល់ជាទៀងទាត់ជាមួយអង្គការសង្គមស៊ីវិលនានា ជាពិសេសជាមួយតំណាងប្រជាជនអ្នកក្រីក្រ។ អង្គការអន្តរជាតិទាំងឡាយគួរតែគាំទ្រផងដែរដល់ការបង្រួបបង្រួមជាសកលរបស់ប្រជាជនក្រីក្រ ដើម្បីឱ្យពួកគេ អាចផ្តល់ដំណឹងចំពោះការពិគ្រោះយោបល់ជាសកល។
សកម្មភាពដែលអនុវត្តន៍ ដោយសាជីវកម្មពហុជាតិដូចជាការប្រកាន់ខ្ជាប់ចំពោះការអនុវត្តវិនិយោគទុនដែលមានក្រមសីលធម៌ និងការគោរពតាមច្បាប់ការងារ ក៏អាចផ្តល់អំណាចដល់អ្នកក្រផងដែរ។

*សន្តិសុខ។* សកម្មភាពទាំងអស់ក៏ត្រូវការចាំបាច់ផងដែរ ដើម្បីកាត់បន្ថយភាពគ្រោះថ្នាក់ពីឥទ្ធិពលអវិជ្ជមានអន្តរជាតិ។ ដោយរួមគ្នាជាមួយរដ្ឋាភិបាល និងវិស័យឯកជន នោះស្ថាប័នហិរញ្ញវត្ថុអន្តរជាតិត្រូវតែពង្រឹងស្ថាបត្យកម្មហិរញ្ញវត្ថុអន្តរជាតិ និងកែ

លំអរការគ្រប់គ្រងរបស់ខ្លួនដើម្បីកាត់បន្ថយភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ដែលវាអាចបំផ្លាញដល់ការរស់នៅរបស់ប្រជាជនក្រីក្រ។ រដ្ឋាភិបាលនៃប្រទេសឧស្សាហកម្មដែលតែងតែរួមសហការជាមួយវិស័យឯកជន គួរតែផ្តល់ការគាំទ្របន្ថែមទៀតចំពោះផលិតកម្មសាធារណៈ ដើម្បីផលិត និងចែកចាយវ៉ាក់សាំងការពារជំងឺអ៊ីវ/អេដស៍ ជំងឺរបេង និងជំងឺគ្រុនចាញ់ និងដើម្បីផលិតនិងផ្សព្វផ្សាយភាពរីកចំរើនខាងកសិកម្មនៅតំបន់ត្រូពិក និងតំបន់ពាក់កណ្តាលហួតហែង។ វិធានការអន្តរជាតិដើម្បីការពារបរិស្ថានអាចជួយកាត់បន្ថយផលប៉ះពាល់ដ៏អាក្រក់នៃការខូចខាតបរិស្ថាន ដែលអាចមានកើតធ្ងន់ធ្ងរនៅប្រទេសក្រីក្រមួយចំនួន។ ហើយសហគមអន្តរជាតិគួរតែព្យាយាមបញ្ឈប់ជំលោះប្រដាប់អាវុធ (ដែលប៉ះពាល់ដល់ខ្លាំងបំផុតដល់ប្រជាជនក្រីក្រ) ដោយចាត់វិធានការកាត់បន្ថយការជួញដូរអាវុធ ជំរុញឱ្យមានសន្តិភាព និងគាំទ្រការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមបន្ទាប់ពីសង្គ្រាមបានបញ្ចប់។

## ធ្វើការរួមគ្នាដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ

យុទ្ធសាស្ត្រនៅក្នុងរបាយការណ៍នេះបានទទួលស្គាល់ថាភាពក្រីក្រគឺមានទំហំច្រើនជាងប្រាក់ចំណូលដ៏តិចតួចឬការអភិវឌ្ឍធនធានមនុស្សដ៏តិចតួចទៅទៀត ព្រោះថាភាពក្រីក្រនេះក៏ជាភាពទន់ខ្សោយ និងជាកង្វះខាតសំលេង អំណាច និងតំណាងផងដែរ។ ជាមួយនឹងទស្សនៈជាច្រើនខាងលើនេះ គេសង្កេតឃើញថាភាពក្រីក្រកាន់តែមានភាពស្មុគ្រស្មាញខ្លាំងឡើងៗនៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ពីព្រោះមានកត្តាជាច្រើន (ដូចជាឥទ្ធិពលសង្គមនិងវប្បធម៌) ចាំបាច់ត្រូវតែយកមកគិតគូរពិចារណា។

មធ្យោបាយដើម្បីដោះស្រាយភាពស្មុគ្រស្មាញនេះ គឺតាមរយៈការផ្តល់អំណាច និងការចូលរួមពីមូលដ្ឋានថ្នាក់ជាតិ និងអន្តរជាតិ។ រដ្ឋាភិបាលថ្នាក់ជាតិគួរតែមានភាពទទួលខុសត្រូវទាំងស្រុងចំពោះប្រជាពលរដ្ឋរបស់ខ្លួនសំរាប់គន្លងអភិវឌ្ឍដែលគេចង់បាន។ យន្តការដែលទាមទារឱ្យមានការចូលរួម អាចផ្តល់សំលេងដល់ស្ត្រី និងបុរស ជាពិសេសចំពោះអ្នកដែលក្រីក្រ និងអ្នកដែលសង្គមមិនរាប់រក។ រចនាបទនៃសេវាកម្ម និងទីភ្នាក់ងាររិមជ្ឈការ ត្រូវការចាំបាច់ដើម្បីឆ្លុះបញ្ចាំងអោយឃើញពីស្ថានភាពនៅតាមមូលដ្ឋាន រចនាសម្ព័ន្ធសង្គម និងបទដ្ឋានវប្បធម៌ និង បេតិកភណ្ឌ។ ស្ថាប័នអន្តរជាតិ គួរតែស្តាប់ និងលើកកំពស់ផលប្រយោជន៍ប្រជាជនក្រីក្រ។ អ្នកក្រីក្រគឺជាតួអង្គសំខាន់នៅក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ ស្ថាប័នអន្តរជាតិទាំងនេះ ត្រូវតែប្រាកដប្រជាចំពោះ ការរៀបចំ ការអនុវត្តន៍ និងការតាមដាននូវយុទ្ធសាស្ត្រប្រឆាំងនឹងភាពក្រីក្រនេះ។

មានតួនាទីសំខាន់ណាស់ចំពោះប្រទេសអ្នកមាន និងអង្គការអន្តរជាតិនៅក្នុងការងារនេះ។ ប្រសិនបើប្រទេសកំពុងអភិវឌ្ឍមួយមានកម្មវិធីផ្ទាល់ខ្លួនដែលមានប្រសិទ្ធភាពនិងមានទំនាក់ទំនងគ្នា សំរាប់ការកាត់បន្ថយភាពក្រីក្រ ប្រទេសនោះគួរតែត្រូវបានទទួលការគាំទ្រយ៉ាងពេញទំហឹង ដើម្បីនាំមកនូវសេវាសុខភាព និងអប់រំសំរាប់ប្រជាជនរបស់ខ្លួន ដើម្បីបំបាត់ការខ្វះខាត និងភាពទន់ខ្សោយ។ ស្របពេលជាមួយគ្នា

នោះដែរ ឥទ្ធិពលរបស់ពិភពលោក ត្រូវតែធ្វើឱ្យមានផលប្រយោជន៍សំរាប់ប្រជាជនក្រីក្រ និងប្រទេសអ្នកក្រ ដើម្បីកុំអោយពួកគេស្ថិតនៅក្រោយភាពជឿនលឿននៃវិជ្ជាសាស្ត្រ និងសុខភាព។ ការបង្កើនស្ថេរភាពបរិស្ថាននិងហិរញ្ញវត្ថុសកល (និងការកាត់បន្ថយឧបសគ្គទីផ្សារលើផលិតផល និងសេវាកម្មនានារបស់ប្រទេសអ្នកក្រ) គួរតែជាផ្នែកសំខាន់បំផុតមួយនៃយុទ្ធសាស្ត្រនេះ។

តើនេះជាពិភពលោកដែលដាច់ចេញពីគ្នាមួយឬ? ឬក៏ជាពិភពលោករួបរួមគ្នាមួយ? តើនេះជាពិភពលោកមួយដែលមានភាពក្រីក្រឬ? ឬក៏ជាពិភពលោកមួយដែលគ្មានភាពក្រីក្រ? សកម្មភាពដែលកើតឡើងក្នុងពេលដំណាលគ្នា ដើម្បីពង្រីកកាលានុវត្តភាព ការផ្តល់អំណាច និងសន្តិសុខ អាចបង្កើតកំលាំងឌីណាមិកថ្មីមួយសំរាប់ការផ្លាស់ប្តូរ ដែលនឹងធ្វើអោយគេមានលទ្ធភាពអាចដោះស្រាយការខ្វះខាតធនធានមនុស្ស និងបង្កើតសង្គមដែលមានលក្ខណប្រកួតប្រជែង និងប្រកបដោយផលិតភាព។ ប្រសិនបើប្រទេសកំពុងអភិវឌ្ឍ និងសហគមន៍អន្តរជាតិធ្វើការរួមគ្នាដើម្បីដាក់បញ្ចូលការយល់ជ្រួតជ្រាបនេះទៅក្នុងធនធានជាក់ស្តែង ទាំងហិរញ្ញវត្ថុនិងអ្វីៗដែលតំណាងអោយប្រជាជន និងទាំងស្ថាប័ននានា (បទពិសោធន៏ចំណេះដឹង និងមនោគតិរបស់ពួកគេ) នោះនៅសតវត្សទី២១នេះ គេនឹងមើលឃើញការរីកចំរើនយ៉ាងលឿននៅក្នុងការប្រយុទ្ធប្រឆាំងដើម្បីបញ្ចប់ភាពក្រីក្រ៕